**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ឋាប់ធ្នាប់ និងសោភ័ណភាពក្រុងព្រះសីហនុ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. អ៊ុក ចន្ទរង្សី**

**ក. ដេត ម៉ានីតា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពក្រុងព្រះសីហនុ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១   ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. អ៊ុក ចន្ទរង្សី**

**ក. ដេត ម៉ានីតា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ក. អ៊ុក ចន្ទរង្សី** និង ឈ្មោះ **ក. ដេត ម៉ានីតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី ២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២១។ យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

**លោកឪពុក អ៊ុក ស៊ីឿន** | **លោកឪពុក ហៀង ដេត**

**អ្នកម្តាយ ទីវ អមរា** | **អ្នកម្តាយ ហ៊ួត ស៊ីណោន**

កូនទាំងពីរសូមសម្តែងនូវភាពកត្តញ្ញូតាធម៌ជាអនេកប្បការ ចំពោះលោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត ខិតខំចិញ្ចឹមបីបាច់ថែរក្សា ការពាររូបកូនតាំងពីក្នុងផ្ទៃ រហូតដល់ពេលនេះ និងបានអប់រំប្រៀនប្រដៅផ្តល់ការសិក្សាចាប់ពីថ្នាក់បឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សានេះ។ លើសពីនេះទៅទៀត លោកទាំងពីរ បានជួយទំនុកបម្រុង ដើរតួនាទីជា គ្រូបង្រៀន និងជាកម្លាំងចិត្តដ៏ខ្លាំងក្លា ក្នុងការសិក្សារៀនសូត្រក្រេបយកចំណេះដឹង ដែលជាស្ពានក្នុងការឆ្លងទៅរកអនាគតល្អ និងភ្លឺស្វាង ។

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត លុយ វណ្ណា** ជាថ្នាក់ដឹកនាំដ៏ខ្ពង់ខ្ពស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំ និងអភិវឌ្ឍន៍កម្មវិធីសិក្សាប្រកបដោយមានគុណភាពល្អ ដោយផ្តល់ឱកាសឱ្យនិស្សិតគ្រប់មជ្ឈដ្ឋានទទួលបានឱកាសក្នុងការចូលរៀននៅក្នុងសាកលវិទ្យាល័យដែលមានកេរ្តិ៍ឈ្មោះ និងកិត្តិនាមល្បីល្បាញមួយនេះ។ ក្រៅពីនេះក៏សូមអរគុណយ៉ាងជ្រាលជ្រៅទៅដល់សាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន និងផ្តល់ដំបូន្មាន ព្រមទាំងឯកសារល្អៗដល់រូបយើងខ្ញុំទាំងពីរ និងនិស្សិតគ្រប់រូប។

ជាពិសេស យើងខ្ញុំសូមគោរពអរគុណចំពោះ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានចំណាយពេលវេលា កម្លាំងកាយ កម្លាំងចិត្តនៅក្នុងការផ្តល់ដំបូន្មាន ចង្អុលបង្ហាញ និងការដឹកនាំសរសេរអត្ថបទសារណាមួយនេះតាំងពីដើម រហូតដល់បានសម្រេចជាស្ថាពរ ។

ជាទីបញ្ចប់ យើងខ្ញុំ សូមជូនពរ លោកឪពុក អ្នកម្តាយទាំងពីរ អ្នកមានគុណទាំងអស់ ឯកឧត្តមបណ្ឌិត លោកបណ្ឌិតសាស្ត្រាចារ្យ សាស្ត្រាចារ្យ ព្រមទាំងក្រុមគ្រួសារឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ជាបឋមក្នុងនាមយើងខ្ញុំ ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី ២១ មានចិត្តសោមនស្សរីករាយក្រៃលែងដោយពួកយើងទាំងពីរនាក់បានធ្វើការពិភាក្សាយ៉ាងល្អិតល្អន់ក្នុងការជ្រើសរើសយកនូវ ប្រធានបទមួយដែលទាក់ទងនឹងមុខវិជ្ជានីតិនគរូបនីយវិទ្យាស្តីពី **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងព្រះសីហនុ។** ចំពោះប្រធានបទមួយនេះគឺ ជាសមិទ្ធផលថ្មីរបស់ពួកយើងទាំងពីរនាក់ ដែលបានរួបរួមកម្លាំងគ្នា ខិតខំ ធ្វើការស្រាវជ្រាវរកឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងប្រធានបទ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីសរសេរជាអត្ថបទសារណាបញ្ចប់ការសិក្សាមួយនេះឡើងឱ្យបានល្អប្រសើរ។

ចំពោះគោលបំណងនៃការសរសេរអត្ថបទសារណានេះឡើង គឺដើម្បីបង្ហាញទៅដល់សាធារណជនឱ្យបានដឹងអំពីទិដ្ឋភាពមួយចំនួនពីរបៀបរៀបរយ ផលវិបាកនិងបញ្ហានានាដែលទាក់ទងទៅនឹងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ទីក្រុងដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់បានចូលរួមក្នុងការរៀបចំក្រុង ឱ្យសមស្របទៅតាមស្តង់ដារទីក្រុងស្អាត។

ម្យ៉ាងវិញទៀតយើងខ្ញុំសង្ឃឹមថាអត្ថបទសារណាមួយនេះនឹងផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍ចំនួនជូនដល់មិត្តអ្នកអាន និងប្អូនៗនិស្សិតជំនាន់ក្រោយដែលមានបំណងចង់ស្វែងយល់ពីប្រធានបទមួយនេះទុកសម្រាប់ជាគំនិតក្នុងការត្រិះរិះពិចារណា និងជាឯកសារជំនួយស្មារតី ដើម្បីផ្តល់ភាពងាយស្រួលក្នុងការសិក្សា។ មួយវិញទៀតយើងខ្ញុំសង្ឃឹមថាស្នាដៃមួយនេះបានចូលរួមចំណែកក្នុងការជំរុញឱ្យរាជធានី-ក្រុង មានការអភិវឌ្ឍសណ្តាប់ធ្នាប់ និងសោភ័ណភាពឱ្យកាន់តែល្អប្រសើរ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់រងចាំទទួលនូវការរិះគន់ពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្សនិស្សិត និង មិត្តអ្នកអានទាំងអស់នូវរាល់កំហុសខុសឆ្គងដែលកើតឡើងដោយអចេតនាដើម្បីជាការចូលរួមកែលម្អអត្ថបទសារណាមួយនេះឱ្យកាន់តែមានប្រសិទ្ធភាពល្អជាងមុនទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១**

**សញ្ញាណនៃការរៀបចំក្រុងព្រះសីហនុ**

**១.១. ទិដ្ឋភាពទូទៅ** ............ ៣

១.១.១. ទីតាំងភូមិសាស្ត្រ ............ ៣

១.១.១.១. ប្លង់គោល ............ ៥

១.១.១.២. តំបន់ទេសចរណ៍ ............ ៦

១.១.១.៣. តំបន់សេដ្ឋកិច្ច ............ ៩

១.១.១.៤. តំបន់នេសាទ ............ ១១

១.១.២. ដង់ស៊ីតេប្រជាជន ............ ១២

**១.២. រចនាសម្ព័ន្ធគ្រប់គ្រងក្រុងព្រះសីហនុ** ............ ១៣

១.២.១. សមាសភាព ............ ១៣

១.២.១.១. ក្រុមប្រឹក្សាក្រុង ............ ១៤

១.២.១.២. គណៈអភិបាលក្រុង ............ ១៦

១.២.២. តួនាទី និងភារកិច្ច ............ ១៦

១.២.២.១. ក្រុមប្រឹក្សាក្រុង ............ ១៧

១.២.២.២. គណៈអភិបាលក្រុង ............ ២០

**១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំក្រុង** ............ ២៥

១.៣.១. កំណើនប្រជាជន ............ ២៦

១.៣.២. កំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ............ ២៧

១.៣.៣. ភាពក្រីក្រ ............ ២៧

**ជំពូកទី២**

**ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ក្រុងព្រះសីហនុ**

**២.១. ការរៀបចំក្រុងព្រះសីហនុ** ............ ២៩

២.១.១. ការរៀបចំសោភ័ណភាពក្រុងព្រះសីហនុ ............ ២៩

២.១.១.១. សោភ័ណភាពពេលថ្ងៃ........................................................................................២៩
២.១.១.២. សោភ័ណភាពពេលយប់........................................................................................៣០
២.១.២. ការរៀបចំសណ្ដាប់ធ្នាប់........................................................................................៣១
២.១.២.១. សន្តិសុខ........................................................................................៣១
២.១.២.២. ភាពស្ងប់ស្ងាត់........................................................................................៣៣
២.១.២.៣. ផាសុកភាព........................................................................................៣៤
២.១.២.៤. កាត់បន្ថយការកកស្ទះចរាចរណ៍នាថ្ងៃឈប់សម្រាក........................................................................................៤០
**២.២. ផលវិបាកនៃការរៀបចំ**........................................................................................៤០
២.២.១. ធនធានមនុស្ស........................................................................................៤១
២.២.២. គម្រោងថវិកា........................................................................................៤១
២.២.៣. កង្វះបច្ចេកទេស........................................................................................៤២
២.២.៤. ការបង្កអោយមានការកកស្ទះចរាចរណ៍........................................................................................៤២
**២.៣. ដំណោះស្រាយ**........................................................................................៤៣
២.៣.១. ការសហការពីប្រជាពលរដ្ឋ........................................................................................៤៣
**សេចក្ដីសន្និដ្ឋាន**........................................................................................៤៤
**អនុសាសន៍**........................................................................................៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់បណ្តាទីក្រុងនៅក្នុងប្រទេសទាំងអស់នៅលើពិភពលោកនេះគឺតែងតែមានការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ ដែលការអភិវឌ្ឍនេះនឹងនាំមកនូវភាពល្អប្រសើរ។ យើងសង្កេតឃើញថារហូតមកទល់ពេលនេះភាពខុសគ្នា និងការប្រែប្រួលរបស់ទីក្រុងពីមួយថ្ងៃទៅមួយថ្ងៃ គឺកាន់តែមានភាពល្អប្រសើរដោយមានភាពស្រស់ស្អាត ទាក់ទាញ បូករួម និងអនាម័យខ្ពស់។ មិនត្រឹមតែប៉ុណ្ណោះ ការរៀបចំទីក្រុងឱ្យប្លែក គឺជាកត្តាមួយដ៏ចម្បងដែលអាចនាំឱ្យប្រទេសជាតិមានភាពរីកចម្រើន និងលូតលាស់ទៅមុខទៀតប្រកបដោយសុខសន្តិភាព។

យ៉ាងណាមិញ ការចាប់ផ្តើមរៀបចំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឡើងវិញពិតជាមានផលលំបាកយ៉ាងខ្លាំង។ តួយ៉ាងចំពោះក្រុងព្រះសីហនុក៏មិនខុសពីក្រុងដទៃទៀតដែរនៅក្នុងប្រទេសកម្ពុជា ទោះបីជាទីក្រុងព្រះសីហនុជាទីកន្លែងមួយដែលមានប្រជាប្រិយភាពជាងគេក៏ដោយ ក៏នៅតែមានកន្លែងមួយចំនួនមិនទាន់បានរៀបចំត្រឹមត្រូវក្នុងការទាក់ទាញភ្ញៀវទេសចរនៅឡើយ ពីព្រោះកន្លែងខ្លះមានភាពស្ងប់ស្ងាត់ពុំសូវមានអ្វីអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ប៉ុន្តែយើងក្រឡេកមើលរយៈពេលប៉ុន្មានឆ្នាំក្រោយនេះអភិបាលក្រុងព្រះសីហនុបានធ្វើការកែសម្រួលទីក្រុងដោយពោរពេញទៅដោយភាពជឿនលឿន ការកែលម្អ ដែលប្រកបដោយសន្តិភាព និងសណ្តាប់ធ្នាប់។ រីឯទីកន្លែងដែលទាក់ទាញភ្ញៀវទេសចរក៏មានការរៀបចំឡើងវិញមានដូចជា កោះ កន្លែងកម្សាន្តផ្សេងៗ ផ្សារ សួនច្បារ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតត្រូវបានរៀបចំកែលម្អដោយមានការតុបតែងភ្លើងពណ៌នាពេលរាត្រីជាដើមដែលបានទាក់ទាញប្រជាពលរដ្ឋដែលរស់នៅទីនោះ ក៏ដូចជាភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យចូលមកទស្សនា និងលេងកម្សាន្ត។

ស្របពេលជាមួយគ្នានេះដែរ ការអភិវឌ្ឍ គឺតែងតែផ្តល់នូវផលអវិជ្ជមាន និង ផលវិជ្ជមានជាច្រើន ដូចជាផលប្រយោជន៍សម្រាប់ប្រទេសជាតិ កំណើនភ្ញៀវទេសចរជាតិ និង អន្តរជាតិ និង កើនឡើងចំណូលជាតិ។ រីឯផលអវិជ្ជមានវិញ ឧទាហរណ៍ជាក់ស្តែង គឺបញ្ហាធនធានធម្មជាតិ និងផលប៉ះពាល់ដល់ប្រជាពលរដ្ឋក្នុងស្រុកមួយចំនួនដែលពាក់ព័ន្ធទៅនឹងការកកស្ទះចរាចរណ៍ជាដើម។ យ៉ាងណាមិញអភិបាលក្រុងក៏បានលេចឡើងនូវដំណោះស្រាយមួយចំនួនផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសង្កេតឃើញថាក្នុងរយៈពេលប៉ុន្មានឆ្នាំខាងក្រោយនេះ ក្រុងព្រះសីហនុមានការរីកចម្រើនយ៉ាងខ្លាំងទាំងការអភិវឌ្ឍ និងការគ្រប់គ្រងទីក្រុង។ ដូចនេះការស្រាវជ្រាវលើប្រធានបទ៖ **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងព្រះសីហនុ** នេះត្រូវធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម ៖

- តើកត្តាអ្វីខ្លះជាមូលហេតុចាំបាច់ក្នុងការរៀបចំក្រុង?
- តើកត្តាអ្វីខ្លះជាមូលហេតុចាំបាច់ក្នុងការរៀបចំសណ្តាប់ធ្នាប់ និង សោភ័ណភាព?

- តើការរៀបចំទាំងនេះផ្តល់ផលប្រយោជន៍ និង ផលវិបាកអ្វីខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវខាងលើនេះ គឺមានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងថ្មីមួយទៀតសម្រាប់ជាជំនួយដល់សិស្សនិស្សិតជំនាន់ក្រោយ និង បុគ្គលដែលមានបំណងចង់ស្វែងយល់ពីចំណេះដឹងទូទៅពាក់ព័ន្ធផែនការយុទ្ធសាស្ត្រក្នុងការរៀបចំក្រុងព្រះសីហនុ និង ចង់បង្ហាញពីសមិទ្ធផល ដែលទទួលបានក្រោយការរៀបចំសណ្តាប់ធ្នាប់រួចនៅក្នុងក្រុងព្រះសីហនុ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺយើងខ្ញុំបានផ្តោតសំខាន់ទៅលើការរៀបចំក្រុងឱ្យមានរបៀបរៀបរយ សណ្តាប់ធ្នាប់ និង សោភ័ណភាពក្នុងក្រុងព្រះសីហនុតែមួយប៉ុណ្ណោះ ពុំមានវិសាលភាពធំធេងទៅលើខេត្តព្រះសីហនុទាំងមូលនោះទេ។ ចំពោះការស្រាវជ្រាវ គឺយើងសិក្សាប្រមូលឯកសារ បទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទខាងលើ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះ សិស្សានុសិស្ស និស្សិត និង មិត្តជំនាន់ក្រោយទុកស្វែងយល់បន្ថែម ដើម្បីជាជំនួយទៅដល់ការសិក្សារបស់ពួកគេនាពេលអនាគត ដោយមានការយល់ដឹងពីយុទ្ធសាស្ត្រនិងនីតិវិធីមួយចំនួនក្នុងការរៀបចំសោភ័ណភាព និង សណ្តាប់ធ្នាប់ក្រុងព្រះសីហនុ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

វិធីនៃការស្រាវជ្រាវប្រធានបទនេះ គឺយើងខ្ញុំទាំងពីរបានធ្វើការពិភាក្សាមតិយោបល់ និងបានទទួលការចង្អុលបង្ហាញពីសំណាក់ **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ពាក់ព័ន្ធទៅនឹងឯកសារនានាដែលមាននៅក្នុងបណ្ណាល័យនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងនៅក្នុងប្រព័ន្ធអ៊ិនធឺណិត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំបានបែងចែកជា ២ ជំពូក គឺ៖

- **ជំពូកទី១ "សញ្ញាណទូទៅនៃការរៀបចំក្រុងព្រះសីហនុ"** ៖ នៅក្នុងជំពូកនេះ យើងខ្ញុំផ្តោតសំខាន់ទៅលើ ៣ ចំណុចសំខាន់ គឺ ទិដ្ឋភាពទូទៅ រចនាសម្ព័ន្ធគ្រប់គ្រងក្រុងព្រះសីហនុ និង កត្តាដែលជំរុញឱ្យមានការរៀបចំក្រុង ។
- **ជំពូកទី២ "ការរៀបចំសោភ័ណភាព និង សណ្តាប់ធ្នាប់"** ៖ នៅក្នុងជំពូកនេះ យើងផ្តោតទៅលើ ៣ ចំណុចសំខាន់ៗ គឺ ការរៀបចំក្រុងព្រះសីហនុ ផលវិបាកនៃការរៀបចំ និង ដំណោះស្រាយ ។

# ជំពូកទី១
# សញ្ញាណនៃការរៀបចំ
# ក្រុងព្រះសីហនុ

# ជំពូកទី១
# សញ្ញាណនៃការរៀបចំក្រុងព្រះសីហនុ

ក្រុងព្រះសីហនុដើមឡើយមានឈ្មោះថា ក្រុងកំពង់សោម បន្ទាប់មកក៏មានការផ្លាស់ប្តូរដោយយកតាមព្រះនាម សម្តេចព្រះ **នរោត្តម សីហនុ** ព្រោះទីក្រុងនេះជាសមិទ្ធផលរបស់ព្រះអង្គដែលបានកសាងឡើង។ ម្យ៉ាងវិញទៀតក្រុងព្រះសីហនុ កំពុងតែទាក់ទាញចំណាប់អារម្មណ៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើនពីព្រោះតែតំបន់មួយចំនួនមានឆ្នេរសមុទ្រស្រស់ស្អាត។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែប្រសើរឡើងក្នុងខេត្តព្រះសីហនុ ត្រូវបានចាត់ទុកជាអាទិភាពមួយសម្រាប់ប្រទេស។ រដ្ឋាភិបាល បានកំណត់ផែនការរៀបចំប្លង់គោលប្រើប្រាស់ដីធ្លីក្នុងខេត្តព្រះសីហនុជាប៉ូលអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជាតាមរយៈ ការអភិវឌ្ឍទីក្រុងទំនើប រមណីយដ្ឋានឆ្នេរសមុទ្រ ដែលស្អាតបំផុតលើសកលលោក និងជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងច្រកចេញចូលអន្តរជាតិមជ្ឈមណ្ឌលភស្តុភារធម្មជាតិឱ្យមានបច្ចេកទេសទំនើបជឿនលឿន។

តួយ៉ាងការកសាងក្រុង និងរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងខេត្តព្រះសីហនុត្រូវបានអនុវត្តដោយរក្សាបាននូវសក្តានុពលធម្មជាតិ និងបរិស្ថានដូចជាតំបន់ឆ្នេរសមុទ្រទេសភាពនគរូបនីយកម្ម ជាពិសេសត្រូវបានតភ្ជាប់សក្តានុពលតំបន់ឆ្នេរឱ្យមានទំនាក់ទំនងគ្នាតាមរយៈការស្ថាបនាផ្លូវ និងស្ពាន។ មិនត្រឹមតែប៉ុណ្ណោះ មានការរៀបចំទីកន្លែងសាធារណៈ ការរៀបចំសម្អាតឆ្នេរសមុទ្រឱ្យមានសោភ័ណភាព ដោយមានទីកន្លែងស្អាតព្រមទាំងធានាបាននូវសុខសុវត្ថិភាពសណ្តាប់ធ្នាប់ល្អក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ និង អន្តរជាតិចូលមកលេងកម្សាន្តប្រកបដោយផាសុកភាព និង អនាម័យផងដែរ។

## ១.១. ទិដ្ឋភាពទូទៅ

### ១.១.១. ទីតាំងភូមិសាស្ត្រ

ខេត្តព្រះសីហនុ ជាខេត្តដែលមានសក្តានុពលសេដ្ឋកិច្ច កំពង់ផែស្វយ័ត តំបន់សេដ្ឋកិច្ចពិសេស ព្រលានយន្តហោះអន្តរជាតិ និង ឆ្នេរសមុទ្រដ៏ស្រស់ស្អាត ដែលមានទីតាំងស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា។ ខេត្តមានប្រជាជនពលរដ្ឋរស់នៅចំនួន ៤៦ ៤៨៧គ្រួសារ មានប្រជាជនសរុប **២១៤ ៦៣០**នាក់ ក្នុងនោះស្ត្រី **១០៨ ០២១**នាក់(របាយការណ៍ឆ្នាំ២០១៨)។ មិនត្រឹមតែប៉ុណ្ណោះ ចំពោះក្រុងព្រះសីហនុ គឺជាក្រុងទេសចរណ៍ធម្មជាតិមួយដែលមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកព្រៃនប់ និង ស្រុកស្ទឹងហាវ ខាងលិចជាប់នឹងស្រុកព្រៃនប់មានផ្ទៃសរុប **១៩៥.៩០** គីឡូម៉ែត្រការ៉េមានប្រជាជនសរុប **៧,៦៥៧** នាក់។ ខេត្តព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជាជាប់នឹងឆ្នេរសមុទ្រមានចម្ងាយ **២៣០**ម៉ែត្រ ពីរាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ

៤ និងចម្ងាយ **២៦០** គីឡូម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ ៣ និងមានផ្លូវដែកឆ្លងកាត់តាមខេត្តកណ្តាល តាកែវ និងកំពត ហើយមានព្រំប្រទល់ដូចខាងក្រោម ៖

- ប៉ែកខាងកើត ជាប់នឹងខេត្តកំពត និងខេត្តកំពង់ស្ពឺ
- ប៉ែកខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រថៃឡង់
- ប៉ែកខាងជើងជាប់នឹង ខេត្តកោះកុង។

ខេត្តព្រះសីហនុចែកចេញជា **២** ក្រុង គឺក្រុងព្រះសីហនុ និង ក្រុងកោះរ៉ុង ៣ ស្រុក ស្រុកព្រៃនប់ ស្រុកស្ទឹងហាវ និងស្រុកកំពង់សីលា។ ទូទាំងខេត្តព្រះសីហនុ ចែកចេញជា ២៩ ឃុំ-សង្កាត់ ព្រមទាំងមាន ១១១ ភូមិ។

ខេត្តព្រះសីហនុមានផ្ទៃដីសរុប **២.៦៥៨,៩០** គីឡូម៉ែត្រការ៉េ មានស្ថានភាពផ្ទៃដី ២/៣ ជាដីព្រៃ ភ្នំ និងខ្ពង់រាប មានឆ្នេរសមុទ្រប្រវែង ១៧៥,៨គីឡូម៉ែត្រ និង មានកោះតូច ធំ ចំនួន ៣២កោះ និងមានធនធានធម្មជាតិដែលមានព្រៃកោងកាង ចំនួន ១៣,៥០០ ហិចតា ផ្កាថ្មចំនួន ១.១៩៨ ហិចតា និងស្មៅសមុទ្រចំនួន ២.៧០ ហិចតា។ មួយវិញទៀតក្រុងព្រះសីហនុមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកព្រៃនប់ និង ស្រុកស្ទឹងហាវ ហើយខាងត្បូងជាប់នឹងស្រុកព្រៃនប់ ដែលមានផ្ទៃក្រឡាបេក្ខភាព ១៩៥ ៩០ គម$^{២}$។

ក្រុងព្រះសីហនុចែកចេញជា **០៤** សង្កាត់ និង **១៥** ភូមិ :

- សង្កាត់លេខ ០១ មាន ៣ ភូមិ គឺ ភូមិ ១, ភូមិ ២ និង ភូមិ ៣។

- សង្កាត់លេខ ០២ មាន ៣ ភូមិ គឺ ភូមិ ១, ភូមិ ២ និង ភូមិ ៣។

- សង្កាត់លេខ ០៣ មាន ៣ ភូមិ គឺ ភូមិ ១, ភូមិ ២ និង ភូមិ ៣។

- សង្កាត់លេខ ០៤ មាន ៦ ភូមិ គឺ ភូមិ ១, ភូមិ ២, ភូមិ ៣, ភូមិ ៤, ភូមិ ៥ និង ភូមិ ៦ ។ ម្យ៉ាងវិញទៀតក្រុងព្រះសីហនុក៏បានបង្កើតហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ **៣៤** ខ្សែ ប្រវែង **៨៤ ៥០៥** ម៉ែត្រ ដែលចែកចេញជាបីប្រភេទដូចជា៖

- **ប្រភេទទី ១** ៖ មហាវិថី មានចំនួន ៣ខ្សែ ប្រវែងសរុប ២១ ៦៨០ ម៉ែត្រ មានទទឹង ៥០ម៉ែត្រ ផ្លូវរថយន្ត៦ គន្លង ផ្លូវទោចក្រយានយន្ត ២គន្លង និង មានសួនពុះចែកទ្រូងផ្លូវនៅចំកណ្តាលផងដែរ។
- **ប្រភេទទី ២** ៖ វិថី មានចំនួន ១៤ខ្សែ ប្រវែងសរុប ៤៩ ៩៥៧ ម៉ែត្រ មានទទឹងពី ២០ ម៉ែត្រ រថយន្ត ២ ទៅ ៤ គន្លង ផ្លូវទោចក្រយានយន្ត ២គន្លង។
- **ប្រភេទី ៣** ៖ អនុវិថី មានចំនួន ១៧ខ្សែ ប្រវែងសរុប ១១ ៨១៧ម៉ែត្រ មានទទឹងពី ៨ ម៉ែត្រ ទៅ ៤០ម៉ែត្រ ចែកជាផ្លូវរថយន្ត ២ គន្លង និង ផ្លូវទោចក្រយានយន្ត ២គន្លង។

ខេត្តព្រះសីហនុ ជាតំបន់ទេសចរណ៍ ដែលមានសក្តានុពលខ្ពស់ ហើយពេញនិយមនៅក្នុងចំណោមតំបន់ទេសចរណ៍ទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលបានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកលេង

កម្សាន្ត។ ជាមួយគ្នានេះដែរ ក្រុងព្រះសីហនុ ជាទីក្រុងមួយដែលមានប្រជាប្រិយភាពដ៏អស្ចារ្យ ដោយសារតែជាទីក្រុងមានសក្តានុពលផ្នែកសេដ្ឋកិច្ច។ ក្រុងព្រះសីហនុជាទីក្រុងមួយ ដែលសំបូរទៅដោយសមុទ្រដែលមានទេសភាពល្អជាទីគាប់ចិត្ត និង ជាពិសេសបង្កភាពងាយស្រួលទៅដល់ផ្នែកសេដ្ឋកិច្ច ដូចជា ការប្រកបរបរចិញ្ចឹមជីវិត និង ការនេសាទជាដើម ។

**១.១.១.១.ប្លង់គោល**

ប្លង់គោលអភិវឌ្ឍន៍នីមួយៗ ឬប្លង់ប្រើប្រាស់ដី គឺពិតជាមានសារៈសំខាន់ខ្លាំងបំផុត ដោយសារតែ ប្លង់គោលជាអ្នកតម្រង់ទិសក្នុងការរៀបចំបែងចែក ហើយបានផ្ទៃដីសម្រាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈ តំបន់សម្រាប់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍ និង បានកំណត់ពីទំហំផ្លូវ ដើម្បីកំណត់ពីផែនការប្រើប្រាស់ដីធ្លី នៅក្នុងមូលដ្ឋានណាមួយមានភាពសមស្រប ដើម្បីជំរុញការប្រើប្រាស់ដី និងការអភិវឌ្ឍប្រកបដោយនិរន្តភាព។ សម្រាប់ផែនការអភិវឌ្ឍន៍ក្រុងនីមួយៗត្រូវឈរលើប្លង់គោល ឬ ប្លង់គោលប្រើប្រាស់ (Master Plan) ដែលជាផែនការកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្ររួម សម្រាប់ការអភិវឌ្ឍរូបវ័ន្ត និងកំណត់អំពីប្រភេទប្រើប្រាស់ដី ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង គមនាគមន៍សំខាន់ៗនៃទីក្រុង និងការធ្វើសមាហរណកម្ម។

មួយវិញទៀត ប្លង់គោលត្រូវភ្ជាប់មកជាមួយគម្រោងអភិវឌ្ឍន៍ទីក្រុងតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង។[1]

ជាក់ស្តែង អភិបាលក្រុងបានរៀបចំប្លង់គោល ប្រើប្រាស់ដីធ្លី ក្នុងខេត្តព្រះសីហនុ តាមចក្ខុវិស័យឆ្នាំ ២០៣០ គឺរៀបចំ និងអភិវឌ្ឍន៍ព្រះសីហនុ ជាប៉ូលអភិវឌ្ឍជាតិ ប្រកបដោយចីរភាព នៅតំបន់ឆ្នេរសមុទ្រកម្ពុជា។ ក្រុងព្រះសីហនុនឹងប្រែមុខមាត់ថ្មីក្រោយការកសាងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំ។

**សម្តេចតេជោ** មានប្រសាសន៍ថា «រដ្ឋាភិបាលកម្ពុជា បានកំណត់ផែនការ រៀបចំប្លង់គោលប្រើប្រាស់ដីធ្លីក្នុងខេត្តព្រះសីហនុ តាមចក្ខុវិស័យឆ្នាំ២០៣០ គឺ រៀបចំ និងអភិវឌ្ឍន៍ខេត្តព្រះសីហនុ ជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាព នៅតំបន់ឆ្នេរសមុទ្រកម្ពុជា»។ ជាពិសេសទៅទៀតនោះ តាមរយៈការអភិវឌ្ឍទីក្រុងទំនើបរមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក និងជាតំបន់សេដ្ឋកិច្ចពិសេស គំរូពហុបំណង ច្រកចេញចូលអន្តរជាតិ ដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាន និងទីផ្សារសកលលោក ដែលជាមជ្ឈមណ្ឌលឧស្សាហកម្ម ផលិតកម្ម បែបបច្ចេកវិទ្យាទំនើប នាពេលខាងមុខ។

បើយោងទៅតាម នីតិវិធី និងដំណើរការនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីទីប្រជុំជន គណៈកម្មាធិការ និងការរៀបចំដែនដីនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម៖

[1] សេចក្តីព្រាងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា១២

- ប្រមូល សម្រង់ ចងក្រង និងវិភាគទិន្នន័យ
- រៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ គំនូសប្លង់ ផែនការសកម្មភាពនិងសេចក្តីណែនាំអនុវត្ត ការគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស និង ការសាងសង់ ព្រមទាំងរបាយការណ៍បច្ចេកទេស
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បិទផ្សាយជាសាធារណៈ នូវសេចក្តីព្រាងចុងក្រោយនៃ ការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីរយៈពេល ៣០(សាមសិប) ថ្ងៃ ដើម្បីទទួលមតិយោបល់សាធារណៈឬការតវ៉ាផ្សេងៗ
- ធ្វើការបូកសរុបមតិសាធារណៈក្នុងរយៈពេលមិនលើសពី ៣០(សាមសិប) ថ្ងៃ ថ្នាក់រាជធានី ខេត្ត ពិនិត្យ និងផ្តល់ការឯកភាព។ ក្នុងករណីដែលតម្រូវឱ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល ៣០(សាមសិប) ថ្ងៃ ខាងលើនេះ អាចត្រូវបានបន្ថែមរយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃទៀតនៃថ្ងៃធ្វើការឬស្របតាមទំហំការងារជាក់ស្តែង។
- គណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មថ្នាក់ខេត្ត ត្រូវត្រួតពិនិត្យ ផ្តល់ការឯកភាព និង ធ្វើសំណើសុំសម្រេចចុងក្រោយពីគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្មថ្នាក់ជាតិ ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីដែលតម្រូវឱ្យមានការកែសម្រួលសេចក្តីព្រាងចុងក្រោយរយៈពេល ៦០(ហុកសិប) ថ្ងៃ ខាងលើនេះ អាចត្រូវបានបន្ថែមស្របតាមទំហំការងារជាក់ស្តែង ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។[2]

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនៅទីក្រុងមុនពេលកំណត់ អាចប្រព្រឹត្តិទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ។

**១.១.១.២. តំបន់ទេសចរណ៍**

ទេសចរណ៍ គឺជាវិស័យមួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនចំណូលសេដ្ឋកិច្ច។ ដោយយោងទៅតាមសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានឱ្យឃើញថា សក្តានុពលនៃវិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាវិស័យដែលមានអាទិភាព ពីព្រោះវិស័យនេះបង្កើតបាននូវកាឡានុវត្តភាពការងារ លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មិនត្រឹមតែប៉ុណ្ណោះបាន

[2] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា១៦និង មាត្រា១៧

ទាក់ទាញការវិនិយោគផ្ទាល់ពីបណ្ដាជនបរទេស និងរូបិយប័ណ្ណអន្តរជាតិដែលជាកត្តាក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។[3]

គួយ៉ាង ក្រុងព្រះសីហនុ មានកន្លែងទេសចរណ៍ និងកន្លែងដំណើរកម្សាន្ត បូករួមនឹងអាហារស្រស់ៗជាច្រើនដូចតទៅ៖

- **ឆ្នេរអូរឈើទាល** ៖ មានទីតាំងស្ថិតនៅក្នុង ខេត្តព្រះសីហនុនៃប្រទេសកម្ពុជា។ ឆ្នេរនេះត្រូវបានគេស្គាល់ថាជាឆ្នេរអ៊ីនតាក់នៅដើមទសវត្សទី ៩០ ហើយពេលនេះវាមានប្រជាប្រិយភាពជាងគេនៅខេត្តព្រះសីហនុ ដោយមានឆ្នេរខ្សាច់ ៤ គីឡូម៉ែត្រ សំរាប់ភ្ញៀវទេសចរ ទឹកពណ៌ខៀវភ្លឺថ្លា និងដើមត្នោត បូករួមអាហារ សមុទ្រល្អបំផុត។ មិនត្រឹមតែប៉ុណ្ណោះ មានការផ្តល់ជូននូវហាងកាហ្វេ បារ សណ្ឋារគារ និងបឹងហ្គាឡូ ក្នុងការស្នាក់នៅកម្សាន្តថែមទៀតផង។
- **ឆ្នេរអូរត្រេះ** ៖ មានទីតាំងស្ថិតនៅភូមិដំណាក់ស្តេចជិតក្រុងព្រះសីហនុនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីឆ្នេរអូរឈើទាលវាជាឆ្នេរដែលមានភ្ញៀវទេសចរចូលទស្សនាច្រើនបំផុតលំដាប់ទី២។ វាក៏មានប្រជាប្រិយភាពផងដែរក្នុងចំណោមប្រជាជនក្នុងស្រុកវ័យក្មេងដែលមកដល់ទីនេះក្នុងអំឡុងពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកដើម្បីទទួលបានភាពស្រស់ស្រាយ។ ដោយមានការយកចិត្តទុកដាក់ខ្ពស់ ក្នុងការរៀបចំកែលម្អនៅតាមតំបន់ឆ្នេរក្នុងក្រុងព្រះសីហនុ ដូចនេះក្រុងព្រះសីហនុបានក្លាយជាទីក្រុងដ៏ទំនើបមួយ នៅក្នុងការទទួលភ្ញៀវទេសចរជាតិ និង អន្តរជាតិឱ្យទៅកម្សាន្តជាមួយគ្នានេះដែរ ។
- **ឆ្នេរឯករាជ្យ ៖** មានទីតាំងស្ថិតនៅ ខេត្តព្រះសីហនុ ហើយមានចម្ងាយប្រហែល ៤គីឡូម៉ែត្រ ពីរង្វង់តោពីរ។ ឆ្នេរឯករាជ្យបានក្លាយជាឆ្នេរដែលបានទាក់ទាញ និង ពេញនិយមសម្រាប់ អ្នកទេសចរជាតិ និងអន្តរជាតិ ដោយសារតែឆ្នេរនេះមានសួនច្បារ មានកន្លែងហាត់ប្រាណ និងកន្លែងចតយានយន្តដោយមានសណ្តាប់ធ្នាប់ត្រឹមត្រូវ ។
- **ឆ្នេរសុខា ៖** មានទីតាំងស្ថិតនៅខេត្តព្រះសីហនុ ហើយមានចម្ងាយប្រហែល ពីរ គីឡូម៉ែត្រពីរង្វង់តោពីរ ឆ្នេរសុខាលាតសន្ធឹងវែងបន្តពីឆ្នេរអូរឈើទាល ហើយសព្វថ្ងៃត្រូវបានវិនិយោគទុនជាមួយក្រុមហ៊ុនសុខាអូតែលរបស់ **លោកឧកញ៉ា សុខ គង់**។ ចំណុចពិសេសរបស់ឆ្នេរនេះ គឺភ្ញៀវទេសចរដែលមកពីឆ្ងាយអាចធ្វើការស្នាក់នៅសណ្ឋាគារសុខាក៏បានដែរ ។
- **កោះថ្មី ៖** មានទីតាំងស្ថិតនៅ ឧទ្យានជាតិរាម ខេត្តព្រះសីហនុ។ កោះថ្មី គឺជាទីជម្រករបស់សត្វមួយចំនួនដូចជា ស្វា សំពោច ពពួកសត្វល្មូន និង សត្វបក្សីជាច្រើនប្រភេទទៀត ដែលអាចឱ្យភ្ញៀវមកលេងទស្សនានៅទីនេះ និង ដើរកម្សាន្តតាមឆ្នេរសមុទ្រ។ ចំណុចពិសេសរបស់កោះថ្មី គឺមានទេសភាពយ៉ាងស្រស់ស្អាតដោយ

[3] គេហទំព័រ https://kohsantepheapdaily.com.kh/article/129293.html (ចូលទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២១)

អមជាមួយព្រៃកោងកាងនៅជុំវិញយ៉ាងខៀវស្រងាត់។ លើសពីនេះអ្នកទេសចរក៏អាចទស្សនាសត្វព្រៃ បក្សាបក្សីជាច្រើនប្រភេទដែលមាននៅទីនោះ ហើយអ្នកទេសចរក៏អាចទៅស្នាក់នៅទីនោះ និង ទទួលបានសេវាកម្មជាច្រើនទៀត មានដូចជា ការជិះទូកមើលផ្កាថ្ម និង ស្ទូចត្រី, បោះជំរុំ ឬ បោះតង់ ជាដើម ។

- **ឆ្នេរកោះពស់ ៖** មានទីតាំងស្ថិតនៅ ខេត្តព្រះសីហនុ មានចម្ងាយប្រហែល ៨ គីឡូម៉ែត្រ ពីរង្វង់មូលតោពីរ។ ឆ្នេរកោះពស់ ជាកោះមួយនៅដាច់ពីឆ្នេរសមុទ្រដទៃទៀត យ៉ាងណាមិញអ្នកទេសចរទៅលេងទីនោះភាគច្រើនវេចខ្ចប់អាហារទៅជាមួយដែរ។

- **វត្តលើ ៖** ដែលមានទីតាំងស្ថិតនៅលើភ្នំព្រះសីហនុមានចម្ងាយតែ ៦ គីឡូម៉ែត្រពីទីរួមខេត្ត។ វត្តលើខេត្តព្រះសីហនុមិនត្រឹមតែជាទីតាំងសាសនានិងជាប្រវត្តិសាស្ត្រប៉ុណ្ណោះទេវាក៏សំខាន់ផងដែរពីចំណុចស្ថាបត្យកម្ម។ វត្តលើបានក្លាយជាកន្លែងសម្រាប់ទាក់ទាញភ្ញៀវទេសចរជាច្រើន ដោយហេតុថាវត្តនេះត្រូវព័ទ្ធជុំវិញដោយជញ្ជាំងថ្មខ្ពស់ បូករួមរូបចម្លាក់ដំរី ៣ ក្បាលឆ្លាក់យ៉ាងស្រស់ស្អាតចេញពីជញ្ជាំងថ្មដោយមានរូបសំណាកព្រះពុទ្ធចំនួន ៣ នៅលើក្បាលដំរីទាំង ៣ និង ប្រាសាទពណ៌មាស ដែលមានដំបូលប្រក់ស្បូវនិងការរចនាបែបបុរាណ។

- **ឆ្នេរខ្សាច់កោះឫស្សី ៖** ជាកោះដ៏សែនស្រស់ស្អាត ដែលមានផ្ទៃទឹកពណ៌ខៀវ ឆ្នេរស្រស់បំព្រង មានខ្សាច់ពណ៌ផ្កាឈូក ឬ ក្រហមជាមួយព្រៃយ៉ាងក្រាស់ លើសពីនេះទៅទៀតភ្ញៀវអាចមើលទស្សនីយភាពដ៏ច្បាស់នាពេលថ្ងៃលិច ហើយភ្ញៀវក៏អាចចុះហែលទឹក មើលផ្កាថ្ម និងកូនត្រីសមុទ្រ ដ៏ស្រស់ស្អាតផងដែរ នៅទីនោះមានរីស៊ត និង បារដែលយើងអាចលេងកម្សាន្តបានយ៉ាងសប្បាយ។

- **ដើមឈើចាំស្នេហ៍ និង សិលាចាំស្នេហ៍ ៖** គឺស្ថិតនៅពាក់កណ្តាលផ្លូវបេតុងឆ្ពោះទៅឆ្នេរអូរត្រេះ និង ឆ្នេរអូរឈើទាល ។ យោងទៅតាមប្រសាសន៍របស់ **លោក គួច ចំរើន** អភិបាលខេត្តព្រះសីហនុ បានលើកឡើងថាដើមឈើនេះ គឺជាប្រភេទដើមជ្រៃត្រាងមានកម្ពស់ ១៥ ម៉ែត្រ ដែលមានអាយុកាលយូរឆ្នាំមកហើយ រីឯសិលាចាំស្នេហ៍ គឺជាថ្មាំងធម្មជាតិមួយយ៉ាងធំ។ ដើមឈើនេះបានក្លាយជាគ្រឿងលម្អក្នុងការទាក់ទាញភ្ញៀវទេសចរទៅកម្សាន្តលេង និងថតរូបអនុស្សាវរីយ៍នៅក្នុងខេត្តព្រះសីហនុ។[4]

- **រមណីយដ្ឋានទឹកជ្រោះក្បាលឆាយ ៖** មានទីតាំងស្ថិតនៅ ក្នុងខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ ដែលមានចម្ងាយប្រមាណ ១៦ គីឡូម៉ែត្រពីភាគខាងជើងនៃទីប្រជុំជនខេត្តព្រះសីហនុ។ ទឹកជ្រោះនេះត្រូវបានគេរកឃើញនៅក្នុងឆ្នាំ ១៩៦០ ទឹកជ្រោះនេះកើតចេញពីប្រភពជាច្រើននៅតាមបណ្តោយជួរភ្នំហើយមានកម្ពស់ ១៤ ម៉ែត្រ។ នារដូវវស្សាពីខែ កក្កដា ដល់ ខែ តុលា មានទេសភាពគយគន់ល្អបំផុត ដោយមានពពុះពណ៌សនៃទឹកល្បាក់ធ្លាក់ចុះ។ ចំណែកឯ ក្នុងអំឡុងរដូវប្រាំងវិញពុំសូវមានទឹកគ្រប់គ្រាន់ក្នុងការលេងលំហែកាយ ប៉ុន្តែមានសម្រស់បែបធម្មជាតិខៀវស្រងាត់លាយឡំ និង បរិយាកាសទឹកជ្រោះ បានផ្តល់នូវភាពស្រស់ស្រាយ។ មិនត្រឹមតែប៉ុណ្ណោះ

[4] គេហទំព័រ https://thmeythmey.com/?page=detail&id=92448 (ចូលទស្សនាចុងក្រោយថ្ងៃទី៥ មិថុនា ២០២១)

រមណីយដ្ឋាននេះក៏បានផ្តល់ជូននូវអាហារសម្បូរបែប ដែលអាចកម្មង់ទៅតាមតម្រូវការ។ ដោយមានការយកចិត្តទុកដាក់ខ្ពស់ ក្នុងការរៀបចំកែលម្អនៅតាមតំបន់ឆ្នេរក្នុងក្រុងព្រះសីហនុ។ ក្រុងព្រះសីហនុបានក្លាយជាទីក្រុងដ៏ទំនើបមួយ ដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើនទៅលេងកម្សាន្ត។ ម្យ៉ាងវិញទៀត ខេត្តព្រះសីហនុសម្បូរទៅដោយទេសភាពស្រស់ស្អាត និង ប្រជុំកោះជាច្រើនផងដែរ ។[5]

**១.១.១.៣. តំបន់សេដ្ឋកិច្ច**

សេដ្ឋកិច្ច បានដើរតួដ៏សំខាន់នៅក្នុងការជំរុញការអភិវឌ្ឍរបស់ប្រទេសជាតិ ពីព្រោះសេដ្ឋកិច្ចគឺជាសិល្បៈក្នុងការចាត់ចែងចំណូល ចំណាយនៃថវិការបស់រដ្ឋ ឬ ប្រទេសណាមួយ។ តួយ៉ាងខេត្តព្រះសីហនុមានភាពរីកចម្រើននៃសេដ្ឋកិច្ចយ៉ាងខ្លាំងក្លាដោយការពឹងផ្អែកទៅលើប្រភពសក្តានុពលជាច្រើន ដែលមាននៅក្នុងខេត្តដូចជា ៖ តំបន់អភិវឌ្ឍន៍ទេសចរណ៍(រមណីយដ្ឋានធម្មជាតិតំបន់កោះឆ្នេរខ្សាច់) តំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម (តំបន់សេដ្ឋកិច្ចពិសេស កំពង់ផែអន្តរជាតិ កំពង់ផែខុកញ៉ាម៉ុង កំពង់ផែស្វយ័តស្ទឹងហាវ និង ក្រុមហ៊ុននាំចេញនាំចូលក្នុង និងក្រៅប្រទេស) តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម (រោងចក្រ សហគ្រាស អគ្គិសនី ទឹកស្អាត)។ល។

សក្តានុពលទាំងនោះជាកត្តាសំខាន់បម្រើដល់ការអភិវឌ្ឍខេត្ត ដែលជួយដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ នៅដើមឆ្នាំ ២០១៦ ក្នុងកម្រិតអត្រាភាពក្រីក្រមានប្រមាណ ១២,៧២% តាមលទ្ធផលវិភាគផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ កំណើនសេដ្ឋកិច្ចថ្នាក់ខេត្ត មាន ៨,៣% និងប្រាក់ចំណូលក្នុងពលរដ្ឋម្នាក់ៗមានចំនួន ១.៨៣៥,២០ ដុល្លារ។

- **តំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម**

- តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ នៃព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងខេត្តព្រះសីហនុនាទិសនិរតីនៃប្រទេសហើយមានទីតាំងនៅចំកណ្តាលក្នុងចំណោមប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាសហគ្រាសសាធារណៈ ដែលមានគុណភាពប្រតិបត្តិការ ប្រហាក់ប្រហែលនឹងកំពង់ផែនានាក្នុងតំបន់ ក៏ដូចជាសកលលោក។ កំពង់ផែស្វយ័តក្រុងព្រះសីហនុផ្តល់សេវាកម្មដែល មានគុណភាពល្អ ឆាប់រហ័ស ទាន់ពេលវេលា តំលៃសមស្រប និង មានលក្ខណៈប្រកួតប្រជែងជាមួយកំពង់ផែផ្សេងៗទៀតក្នុងតំបន់ដោយមានសេវាកម្មសំខាន់ៗដូចខាងក្រោម ៖

  ១ - សេវាកម្មនាវាចរ

  ២ - សេវាលើកដាក់ទំនិញ

  ៣ - សេវាស្តុកទំនិញ

[5] គេហទំព័រ http://vokc.org/article/167 (ចូលទស្សនាចុងក្រោយថ្ងៃទី៥ មិថុនា ២០២១)

៤ - សេវាដឹកជញ្ជូន

៥ - តំបន់សេដ្ឋកិច្ចពិសេស

៦ - សេវាភស្តុភារ មូលដ្ឋានផ្គត់ផ្គង់ការរុករកប្រេង ។ល។

- **កំពង់ផែឧកញ៉ាម៉ុង ៖** ជាកំពង់ផែសមុទ្រឯកជនដំបូងគេនៅកម្ពុជា ដែលមានទីតាំងស្ថិតនៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ហើយជាកំពង់ផែមួយដើរតួនាទីដ៏សំខាន់នៅក្នុងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម និង ទេសចរណ៍នៃប្រទេសកម្ពុជា ដោយបានផ្តល់សេវាកម្មកំពង់ផែសមុទ្រធំមួយសម្រាប់ការដឹកជញ្ជូនទំនិញ រវាងប្រទេសកម្ពុជា និងប្រទេសដ៏ទៃទៀតលើពិភពលោកមានដូចជា ៖
    1. ក្រុមហ៊ុនបណ្តាក់ទន់រវាង MRG និងក្រុមហ៊ុន TCC Group
    2. ការនាំចូលចម្បងៗ គឺមកពីប្រទេសថៃ ចិន និងម៉ាឡេស៊ី
    3. កំពង់ផែសមុទ្រឯកជនដំបូងគេបង្អស់របស់ប្រទេសកម្ពុជា។[6]
- **កំពង់ផែស្វយ័តស្ទឹងហាវ ៖** ជាតំបន់ផែអន្តរជាតិ ដែលកំពង់ផែអន្តរជាតិស្ទឹងហាវជាកម្មសិទ្ធិរបស់តំបន់ សេដ្ឋកិច្ចពិសេសស្ទឹងហាវ ដែលជាក្រុមហ៊ុនរបស់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។ គោលដៅចម្បងរបស់ កំពង់ផែនេះ គឺដើម្បីពង្រីក ជម្រៅផែពី ៦ ទៅ ១២ ម៉ែត្រដើម្បីឱ្យកប៉ាល់ធំៗចូលចត។ គម្រោងនេះគឺជាកិច្ច សហការរួមគ្នារបស់តំបន់សេដ្ឋកិច្ចភ្នំពេញ និង សាជីវកម្មផ្សារដែកចិន ដែលជាក្រុមស្ថិតក្រោមការគ្រប់គ្រង និង ត្រួតត្រារបស់រដ្ឋាភិបាលចិន ដែលជាសហគ្រាស សំណង់ដែកថែបមួយ ដែលមានដំណើរការយូរជាង គេបំផុតនៅក្នុងប្រទេស។

**តំបន់អភិវឌ្ឍន៍ទេសចរណ៍**

- **ផ្លូវដែក ៖** ផ្លូវដែកក្នុងប្រទេសកម្ពុជាមានប្រវែង **៦៥០** គីឡូម៉ែត្រ ដោយផ្លូវពីភ្នំពេញ ទៅក្រុង ព្រះសីហនុ ឆ្លងកាត់ខេត្តកំពតមានប្រវែង **២៦៤** គីឡូម៉ែត្រ។ ក្នុងនោះផងដែរអ្នកដែលបានធ្វើដំណើរ តាមខ្សែ រថភ្លើងភ្នំពេញ-ព្រះសីហនុ មានចំនួនច្រើនជាងគេ គឺប្រមាណ **១៦.000** នាក់ ចំពោះ ចំនួនទំនិញមានចំនួនសរុបដល់ទៅជាង **៧៥0.000** តោនក្នុងរយៈពេលដូចគ្នា។[7]
- **ផ្លូវអាកាស ៖** ព្រលានយន្តហោះក្រុងព្រះសីហនុ អតីតព្រលានយន្តហោះកេងកង ជាកត្តាដែលធ្វើឱ្យ សេដ្ឋកិច្ចក្រុងព្រះសីហនុមានភាពរីកចម្រើនយ៉ាងខ្លាំង។ ក្រុងព្រះសីហនុកំពុងក្លាយជាតំបន់ដ៏មាន សក្តានុពលខ្ពស់ និងជាទិសដៅទេសចរណ៍សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ។ តួយ៉ាងព្រលានយន្ត

---

[6] គេហទំព័រ MONG RETHTHY GROUP(ចូលទស្សនាចុងក្រោយថ្ងៃទី១៥ មិថុនា ២០២១)

[7] គេហទំព័រ https://construction-property.com/km/the-kingdoms-railway-reopening-how-it-progresses/ (ចូលទស្សនាចុងក្រោយថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១)

ហោះព្រះសីហនុ បានផ្ដល់ភាពងាយស្រួលដល់អ្នកទេសចរបានយ៉ាងច្រើនសម្បើម ចំណែកឯការហោះហើរនៅក្នុងស្រុក បូករួមទាំងអន្តរជាតិដែលអាចធ្វើដំណើរទៅទីក្រុងហូជីមិញ រាជធានីភ្នំពេញ និង សៀមរាបផងដែរ។ ជាពិសេសទៅទៀតនោះក៏មានការផ្ដល់ជូនសេវាយន្តហោះឯកជនអន្តរជាតិ និងឧទ្ធម្ភាគចក្រផងដែរ។

- **តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម ៖** ខេត្តព្រះសីហនុមានផ្ទៃដីសរុបចំនួន **១១,១៣** គីឡូម៉ែត្រការ៉េ ហើយក្នុងនោះមាន **៥,២៨** គីឡូម៉ែត្រការ៉េ ជាតំបន់ឧស្សាហកម្មធំៗ ដែលរួមមានរោងចក្រជាច្រើន ដូចជា ៖ រោងចក្រវាយនភ័ណ្ឌសម្លៀកបំពាក់ រោងចក្រស្រាបៀរអង្គរ រោងចក្រគ្រឿងម៉ាស៊ីន គ្រឿងអេឡិចត្រូនិក និងឧស្សាហកម្មផលិតកម្មផ្សេងទៀត។ សព្វថ្ងៃមានរោងចក្រឧស្សាហកម្មមួយចំនួនដែលកសាងនៅតំបន់សេដ្ឋកិច្ចពិសេស ដែលស្ថិតនៅក្នុងឃុំ បិតត្រាង ស្រុកព្រៃនប់ និង តំបន់ឧស្សាហកម្មមួយទៀតនៃខណ្ឌមិត្តភាព។ ក្រៅពីនេះមានរោងចក្រផលិតធ្យូង ថ្ម ដោយអគ្គិសនីនៅទីនោះផងដែរ។ ក្នុងតំបន់អភិវឌ្ឍន៍ឧស្សាហកម្មបានយកផ្លូវល្បឿនលឿនធ្វើជាជំនួយក្នុងការដឹកជញ្ជូនទំនិញគឺ៖

  - **ផ្លូវល្បឿនលឿន ៖** គឺជាផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ ដែលមានបរិក្ខារបែងចែកទ្រូងផ្លូវជាពីរ ហើយមានចំណែកខុសទិសគ្នា ឬ ចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយ ឬត្រូវមានផ្លូវប្រសព្វតិចបំផុត ក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ដើម្បីធានាលំហូរចរាចរណ៍ សុវត្ថិភាព និង ដើម្បីបន្ថយពេលវេលាធ្វើដំណើរ និង មានកន្លែងកំណត់សម្រាប់ឱ្យយានយន្តចេញ និង ចូលផ្លូវល្បឿនលឿន។ ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុជាខ្សែផ្លូវថ្មីទាំងស្រុង ដែលមានប្រវែងសរុបប្រហែល ១៩០,៦៣៣ គ.ម ។

### ១.១.១.៤. តំបន់នេសាទ

នៅក្រុងព្រះសីហនុ តំបន់នេសាទមានបីសំខាន់ៗ គឺ តំបន់នេសាទទំនប់រលក តំបន់នេសាទកោះខ្យង និងផែនេសាទកំពេញ ស្រុកស្ទឹងហាវ។ មិនមែនត្រឹមតែជាទីកន្លែងទេសចរណ៍ និងជាទីកន្លែងសេដ្ឋកិច្ចដ៏មានសក្ដានុពលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាទីកន្លែងប្រមូលផលនេសាទក្នុងការនាំចេញទៅក្រៅប្រទេស ក៏ដូចជាបំពេញសេវាកម្មក្នុងស្រុក។ ប្រទេសកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលមានការនេសាទ ត្រី ដ៏ច្រើនក្នុងពិភពលោក។

វិស័យជលផលរបស់កម្ពុជា រួមមាន ការនេសាទចិញ្ចឹមក្រពះ និង ការនេសាទទ្រង់ទ្រាយធំ និងការប្រមូលផល ការកែច្នៃ និង ទីផ្សារ។ វិស័យជលផល ដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច សន្តិសុខស្បៀងអាហារ និង អាហារូបត្ថម្ភ ដែលរួមមាន ទឹកសមុទ្រផងដែរ។ ឆ្នេរសមុទ្រ របស់កម្ពុជាបានផ្តល់ទិន្នផល

ខ្ពស់ និង សំបូរទៅដោយធនធានជលផល។ ដោយយោងតាមរបាយការណ៍បូកសរុប ប្រចាំឆ្នាំ ២០១៤ របស់ក្រសួងកសិកម្ម ផលិតកម្មជលផល សរុបគឺ ១២០,២៥០ តោន បានមកពី ជលផល ទឹកប្រៃ ។

យ៉ាងណាមិញតំបន់នេសាទនៅកោះពស់ គឺមានទំហំតូចហើយសកម្មភាពនេសាទ មានរយៈពេលខ្លីបើធៀបទៅនឹងតំបន់នេសាទដទៃទៀតនៅខេត្តព្រះសីហនុ។ ក្នុងរយៈពេលនេសាទត្រីនៅជុំវិញកោះពស់អាចធ្វើការសន្និដ្ឋានលទ្ធផលដូចខាងក្រោម៖

- ប្រាក់ចំណូលមធ្យមប្រចាំថ្ងៃមានចំនួន ១៥០.០០០រៀល/ក្នុងមួយគ្រួសារ ដែលមានទូកនេសាទមួយជាធម្មតាគឺមានមនុស្សពីរនាក់ក្នុងប្រភេទទូកនេសាទបែបនេះ
- ការប៉ាន់ប្រមាណផលចាប់សម្រាប់តំបន់នេសាទកោះពស់គឺមានចំនួន ៦៧,១៥តោន/ឆ្នាំ
- តម្លៃប៉ាន់ប្រមាណសរុបគឺមានចំនួន ១០៧.២១២ដុល្លារអាមេរិក/ឆ្នាំ។[8]

### ១.១.២. ដង់ស៊ីតេប្រជាជន

ក្រុងព្រះសីហនុជាទីក្រុងមួយ ដែលស្ថិតនៅខេត្តព្រះសីហនុ ហើយពោរពេញទៅដោយប្រជាពលរដ្ឋរស់នៅ ប្រកបរបររកស៊ីចិញ្ចឹមជីវិតតាមបែបសាមញ្ញធម្មតា ដូចជា ការប្រកបអាជីវកម្ម កសិឧស្សាហកម្ម ការនេសាទ ដែលជាមូលដ្ឋានបង្កើនសេដ្ឋកិច្ចគ្រួសារ និង ជាខឿននាំឱ្យសេដ្ឋកិច្ចជាតិកាន់តែរីកចម្រើនទៅមុខទៀត។

ក្រុងព្រះសីហនុមានចំនួនប្រជាជនសរុបចំនួន **៧៧ ៦៥៧** នាក់ ស្មើនឹង **១៧ ០០៣** គ្រួសារ ក្នុងនោះស្រីមាន ចំនួន **៣៩ ៥៥៤** នាក់។[9] ដោយសារតែមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ការអភិវឌ្ឍកំពង់ផែការអភិវឌ្ឍទេសចរណ៍ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗទៀតនៅក្នុងខេត្តព្រះសីហនុ ដែលជាកត្តាសំខាន់នៃចំណូលស្រុកនៃប្រជាជនថ្មីមករស់នៅតំបន់ឆ្នេរនេះ។

- **ការនេសាទ ៖** វិស័យជលផល ជាផ្នែកមួយដ៏សំខាន់សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ទន្លេ និង សមុទ្រ ហើយក៏ជាអ្នករួមវិភាគទានដ៏សំខាន់នៅក្នុងខឿនសេដ្ឋកិច្ចជាតិ និង សន្តិសុខស្បៀងផងដែរ។ ចំពោះការនេសាទនេះប្រជាជន ក៏អាចនាំចូលពីរាជធានីភ្នំពេញ ឬតាមបណ្តាខេត្តនានា ដែលអាចធ្វើឱ្យមានការរីកចម្រើនផ្នែកបង្កបង្កើនផលបានមួយកម្រិតថែមទៀតដែរ ដោយមូលហេតុថាប្រជាពលរដ្ឋអាចចេះពីវិធីក្នុងការចិញ្ចឹមត្រី គ្រឿងសមុទ្រផ្សេងៗបាន។
- **អាជីវកម្ម ៖** មុខរបរចម្បងក្នុងការប្រកបអាជីវកម្ម ដែលប្រជាជននៅ ក្រុងព្រះសីហនុ បានប្រកបរបរដូច

[8] គេហទំព័រ https://data.opendevelopmentmekong.net/dataset/dea398c4-4242-480e-ad76-93820a1497d9/resource/a253a536-7032-43bd-b14e-cbef362c3948/download/2-executive-summary. (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១)

[9] គេហទំព័រ https://visitcambodia.travel/kh/province/view/6454a48474t2943423s2 (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១)

ជា ការទិញ ការលក់ទំនិញកសិផល ការទិញ-លក់ភោគផលសមុទ្រ និង ផលិតផលគ្រឿងបរិក្ខារ គ្រឿងឧបភោគ លក់សម្លៀកបំពាក់ គ្រឿងអេឡិចត្រូនិចជាដើម។ មួយវិញទៀតមានផ្នែកជាងជួសជុលក្នុងក្រុងមានដូចជា៖ ជាងជួសជុលរថយន្ត ម៉ូតូ ម៉ាញ៉េ ទូរស័ព្ទ ទូរទស្សន៍ និងគ្រឿងបច្ចេកទេសផ្សេងៗជាដើម។

## ១.២. រចនាសម្ព័ន្ធគ្រប់គ្រងក្រុងព្រះសីហនុ

ជាទូទៅការរៀបចំក្រុងមួយ ដែលប្រកបទៅដោយ សណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ សុវត្ថិភាពនិង សោភ័ណភាពល្អ ចាំបាច់ណាស់ត្រូវតែមានការធ្វើគម្រោងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឱ្យបានត្រឹមត្រូវជាមុនសិនទើបការអនុវត្តមានសុពលភាពល្អ ប្រកបដោយប្រសិទ្ធភាព។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំគឺ ជាមធ្យោបាយយ៉ាងសំខាន់ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់កំណត់អំពីបញ្ហា និងតម្រូវការជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយនូវ បញ្ហាប្រឈមទាំងនោះ ឆ្លើយតបនឹងតម្រូវការ ជាអាទិភាពរបស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព និង ជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។[10] បន្ថែមពីនេះទៅទៀតការគ្រប់គ្រងក្រុងមួយត្រូវធ្វើគម្រោងការសមស្របតាមបរិការណ៍ប្រជាសាស្ត្រ សង្គម និងសេដ្ឋកិច្ច ដែលមានការកំណត់ពីចក្ខុវិស័យច្បាស់លាស់ រួមបញ្ចូលគ្នាទាំងការគិតគូរលើបរិស្ថាន សណ្ឋានដី ជីវចម្រុះ ទិដ្ឋភាព និងការមើលឃើញច្បាស់លាស់។

### ១.២.១. សមាសភាព

សមត្ថកិច្ចដែលមានសារៈសំខាន់ដែលពាក់ព័ន្ធទៅនឹងការរៀបចំក្រុង គឺរដ្ឋបាលក្រុងដែលក្នុងនោះមាន ក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង។

[10] ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ,ប្រការ២




**១.២.១.១. ក្រុមប្រឹក្សាក្រុង**

ក្រុមប្រឹក្សាក្រុង ត្រូវបានបង្កើតឡើងដោយការបោះឆ្នោតជាអសកល តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលជាតំណាងសាធារណៈ ជាអ្នកការពារ និង ជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ច

របស់ខ្លួន។[11] ក្រុមប្រឹក្សាមានអាណត្តិប្រាំឆ្នាំ និង ត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ក្រុងនីមួយៗ ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និង លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ កិច្ចប្រជុំសាមញ្ញលើកទី១៤ អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តព្រះសីហនុ មានរបៀបវារៈចំនួន ៧ យកមកពិនិត្យ និងពិភាក្សា។ ក្រុមប្រឹក្សាក្រុងត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួន បី ដែលតម្រូវឱ្យបង្កើតឡើង ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរួមមាន៖

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការលទ្ធកម្ម។[12]
- គណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម

➢ **កិច្ចប្រជុំក្រុមប្រឹក្សា ៖** ក្រុមប្រឹក្សាមានកិច្ចប្រជុំពីរ គឺកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ ដែលត្រូវធ្វើឡើងជាសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន លើកលែងតែរបៀបវារៈណាមួយដែលតម្រូវឱ្យមានការប្រជុំពិភាក្សាដោយសម្ងាត់។ ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ជាទៀងទាត់យ៉ាងហោចណាស់ចំនួន ១២ ដងក្នុងមួយឆ្នាំ ទៅតាមប្រតិទិនប្រជុំប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញរបស់ខ្លួន នៅពេលណាមួយតាមការចាំបាច់ ដើម្បីពិភាក្សាលើបញ្ហាពិសេស ឬ បន្ទាន់ណាមួយតាមការស្នើឡើងរបស់ប្រធានក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សាចំនួន មួយភាគបី (១/៣) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ឬអភិបាល ឬគណៈអភិបាល។

- **កិច្ចប្រជុំសាមញ្ញ** ៖ ជាកិច្ចប្រជុំដែលក្រុមប្រឹក្សា ត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ ១២ ដងក្នុងមួយឆ្នាំ។
- **កិច្ចប្រជុំវិសាមញ្ញ** ៖ ជាកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដែលធ្វើឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមការចាំបាច់ដើម្បីដោះស្រាយនូវបញ្ហាបន្ទាន់ ឬ ពិសេស។

<u>បញ្ជាក់</u> ៖ កិច្ចប្រជុំក្រុមប្រឹក្សា ត្រូវធ្វើឡើងស្របទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។[13]

[11] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៦១

[12] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាកទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៧៥

[13] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាកទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៦៧ កថាខណ្ឌទី១

- **ក្រុមប្រឹក្សាមានសិទ្ធិអំណាចពីរ គឺ៖**
- សិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ
- សិទ្ធិអំណាចធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិ

ក្រុមប្រឹក្សាក្រុង ត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួន ដោយផ្អែកតាមគោលការណ៍ បែបបទ និង នីតិវិធីដែលកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។[14]

### ១.២.១.២. គណៈអភិបាលក្រុង

នៅតាមបណ្ដាសាលាក្រុងនីមួយៗ ត្រូវតែមានគណៈអភិបាលក្រុង ដែលក្នុងនោះរួមមាន អភិបាលក្រុងមួយរូប និងអភិបាលរងក្រុងមួយចំនួន ដែលត្រូវបានតែងតាំង ដោយស្របតាមលក្ខខណ្ឌ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

<u>**កំណត់ចំណាំ**</u> ៖ អភិបាលក្រុង និងអភិបាលរងក្រុង មិនមែនជាសមាជិកក្រុមប្រឹក្សាក្រុងឡើយ។

- **កិច្ចប្រជុំគណៈអភិបាល ៖** ជាកិច្ចប្រជុំរវាងអភិបាល និង អភិបាលរង នៅក្នុងគណៈអភិបាលរបស់ខ្លួន។

គណៈអភិបាលត្រូវជួបប្រជុំជាទៀងទាត់ប្រចាំអឌ្ឍមាស។ ក្រៅពីកិច្ចប្រជុំអឌ្ឍមាស និង ការប្រជុំប្រចាំខែគណៈអភិបាលជួបប្រជុំតាមការចាំបាច់ទៅតាមសំណើរបស់អភិបាល។ កិច្ចប្រជុំគណៈអភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានអភិបាល អភិបាលរង លើសពីពាក់កណ្ដាលនៃសមាសភាព គណៈអភិបាលទាំងមូល។ ក្នុងករណីមានចំនួនសំឡេងស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្ដមានុភាព។

តួយ៉ាងអភិបាល គឺជាអ្នកកោះប្រជុំ និង ជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីអភិបាលអវត្តមានអភិបាលស្ដីទីជាអ្នកកោះប្រជុំ និង ជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំរបស់គណៈអភិបាល ត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយនាយករដ្ឋបាល និង ត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

### ១.២.២. តួនាទី និងភារកិច្ច

តួនាទី និង ភារកិច្ចដែលត្រូវបានបែងចែកដូចតទៅ ៖ គ្រប់បណ្ដាខេត្ត ក្រុង ទាំងអស់ត្រូវតែមានការគ្រប់គ្រងពីសំណាក់ក្រុមប្រឹក្សាក្រុងឬអភិបាលក្រុង ហើយការគ្រប់គ្រងទៅតាមតំណែងនីមួយៗគឺសុទ្ធសឹងតែមានភារកិច្ច និង តួនាទីដែលត្រូវបំពេញរៀងៗខ្លួនដើម្បីបម្រើទៅដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងដំណើរការងារ មិនឱ្យមានការកកស្ទះផងដែរ។ ដោយយើងបានដឹងហើយថា ដើម្បីរៀបចំក្រុងមួយឱ្យបានល្អដរាបណាមានការចូលរួមចាត់ចែងពីសំណាក់រដ្ឋបាលខេត្ត ក្រុងនីមួយៗដែលនៅក្នុងនោះរួមមាន មុខងារ តួនាទី និងភារកិច្ចមួយចំនួនដែលបានបែងចែកដូចខាងក្រោម ៖

[14] អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៧២

**១.២.២.១. ក្រុមប្រឹក្សាក្រុង**

តួនាទី និង ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាក្រុង គឺចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញនៃការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់និងដែលបានធ្វើប្រតិភូកម្ម។ មួយវិញទៀតក្រុមប្រឹក្សាក្រុងមានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលក្រុងនៅលើកំណត់ហេតុ និងឯកសារដូចតទៅ ៖

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាក្រុង
- សំណើដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុង តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[15]

**ចំពោះភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង មានដូចតទៅ ៖**

- ណែនាំផ្នែកគោលនយោបាយសម្រាប់កសាងផែនការអភិវឌ្ឍន៍ក្រុង
- ពិនិត្យ និង អនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង
- តាមដាន និង វាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង
- ពិនិត្យ និងអនុម័តសំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង ក្នុងករណីចាំបាច់។

**របៀបរបបការងាររបស់ក្រុមប្រឹក្សាក្រុង** ៖ ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

[15] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៦៩ កថាខណ្ឌទី១

- ក្រុមប្រឹក្សាក្រុង ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និង សេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។
- ក្រុមប្រឹក្សាក្រុងអាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ អាចបង្កើតគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការ ឬ ក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬ សេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះគណៈអភិបាលក្រុងត្រូវ ដឹកនាំនាយករដ្ឋបាលសាលាក្រុងនិងការិយាល័យពាក់ព័ន្ធនៃសាលាក្រុង ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។
- ក្រុមប្រឹក្សាក្រុង ត្រូវចាត់ឱ្យអភិបាលក្រុងចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬ សេចក្តីសម្រេចទាំងឡាយដែលក្រុមប្រឹក្សាក្រុង បានអនុម័តរួចលើកលែងតែមានការកំណត់ផ្សេងពីនេះព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។
- ក្នុងករណីកិច្ចការណាមួយ ដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនិតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើ គោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនោះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទនីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ។
- ក្នុងករណីកិច្ចការណាមួយ ដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនសមស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាក្រុងមិនអាចអនុវត្តបាន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ ដោយផ្អែកតាមយន្តការ គ.ជ.អ.ប រដ្ឋមន្ត្រីក្រសួងមហាផ្ទៃធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។

➢ **កិច្ចប្រជុំក្រុមប្រឹក្សា** ៖ រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលក្រុង និងជាវិធានការ បែបបទ នីតិវិធីចាត់ចែងការងារ តាមការចាំបាច់ដែលទាក់ទងនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ដែលស្របតាមច្បាប់ស្តីពី ការគ្រប់គ្រងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការ ដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុង ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានា តាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ដំណើរការពិគ្រោះយោបល់ជាសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- សមិទ្ធផល និងបញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុង ត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សាក្រុង អាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖
- ការកោះអញ្ជើញអភិបាលក្រុង ឬ អភិបាលរងក្រុង ឬ គណៈអភិបាលក្រុងទាំងមូល ឬ បុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង

- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុង យល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និង ការសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលក្រុង អំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការធ្វើប្រតិភូមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងដោះស្រាយ ចំពោះទង្វើមិនស្របច្បាប់ ដែលប្រព្រឹត្តដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬគណៈអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទមូលដ្ឋាន ស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាសនិង ប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលក្រុង
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់។

**១.២.២.២. គណៈអភិបាលក្រុង**

គណៈអភិបាលក្រុងមានភារកិច្ច និង តួនាទីចូលរួមប្រជុំក្រុមប្រឹក្សាក្រុង និងត្រូវជួយដល់ក្រុមប្រឹក្សាក្រុងរបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារសម្រាប់រៀបចំ កិច្ចប្រជុំទាក់ទងនឹងសំណើដកហូតអភិបាលក្រុងឬអភិបាលរងក្រុងចេញពីមុខតំណែងតែប៉ុណ្ណោះ។[16]

**ភារកិច្ចរបស់គណៈអភិបាលសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ មានដូចតទៅ៖**

- ដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ ស្របតាមការណែនាំរបស់ក្រុមប្រឹក្សាក្រុង
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍មុនដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត
- ដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង
- ដាក់សំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង

[16] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា៦៩ កថាខណ្ឌ២

- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង តាមការណែនាំរបស់ក្រុមប្រឹក្សា។[17]

**គណៈអភិបាលក្រុងមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖**

- គណៈអភិបាលក្រុងត្រូវធ្វើការស្រាវជ្រាវ ដើម្បីផ្ដល់យោបល់ជូនក្រុមប្រឹក្សាក្រុង អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖
  - ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬ បានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និង ការចាត់ចែងធនធានទាំងនោះ
  - ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារភារកិច្ច និងធនធាន ដែលបានប្រគល់ ឬបានផ្ទេរ ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
  - គម្រោងថវិកាប្រចាំឆ្នាំ
  - ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុង
  - ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
  - ការរៀបចំតួនាទី ភារកិច្ច និង លក្ខខណ្ឌការងាររបស់បុគ្គលិក
  - ការកំណត់នីតិវិធីរដ្ឋបាល និង ហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុងនិង បុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
  - រៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័តមិនឱ្យលើសពី៤៥ ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង៖
    - ដីកា និង សេចក្ដីសម្រេចនានា ដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និង សកម្មភាពលទ្ធផលនៃការអនុវត្ត
    - របាយការណ៍ហិរញ្ញវត្ថុ
    - ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
    - វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
    - វិធានការចាំបាច់ដើម្បីលើកកម្ពស់យេនឌ័រ

[17] សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង

- កិច្ចការផ្សេងៗទៀត ដែលក្រុមប្រឹក្សាក្រុងយល់ឃើញថា ចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា តាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយពត៌មានដល់សាធារណជន ដូចជាការរៀបចំក្តារពត៌មាន និង ការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និង បញ្ហាប្រឈមនានារបស់សង្កាត់
- ការធ្វើប្រតិភូមុខងារ ភារកិច្ច និង ការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និង ដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន

- នៅពេលបានទទួលរបាយការណ៍ ព័ត៌មានអំពីការរំលោភអំណាច គណៈអភិបាលក្រុងត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាក្រុង និង ធ្វើសេចក្តីរាយការណ៍ ជូនរដ្ឋបាលខេត្តដើម្បីរដ្ឋបាលខេត្តធ្វើ សេចក្តីរាយការណ៍ជូនមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលក្រុងមានតួនាទី ជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងស្រុក។

**ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្រុងត្រូវ៖**

- ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងក្រុងអំពីច្បាប់ និង ធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និង គោរពសិទ្ធិមនុស្ស ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងក្រុង
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពក្រុង ក្នុងការដឹកនាំសម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និង សង្កាត់នៅក្នុងក្រុង ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និង របៀបរៀបរយសាធារណៈនៅក្នុងក្រុង
- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័ន ដែលប្រចាំនៅក្រុងឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់គោលនយោបាយជាតិ និង លិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និង ទីភ្នាក់ងារនីមួយៗនោះ

- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និង ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលក្រុងត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និង តម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួល បច្ចេកទេសក្រុមប្រឹក្សាក្រុង អភិបាលក្រុងត្រូវសម្របសម្រួលតម្រង់ទិស ការិយាល័យអង្គភាព និង ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅក្រុងក្នុងការធ្វើសមាហរណកម្មផែនការនិង ថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាមុន ក្នុងការផ្ដល់យោបល់លើបេក្ខភាព ដែលស្នើតែងតាំងជាប្រធានការិយាល័យ និង អង្គភាពនៃក្រសួងស្ថាប័ននានា ប្រចាំនៅក្រុងរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាព ដែលស្នើតែងតាំងខាងលើនេះ អភិបាលក្រុងត្រូវរាយការណ៍ ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការ សម្របសម្រួលជាមួយប្រធាន មន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្ដីរាយការណ៍ ជូនមន្ត្រី ឬ ប្រធានស្ថាប័នសាមី
- រាយការណ៍ជាលាយលក្ខណ៍អក្សរ និង ជាបន្ទាន់ទៅអភិបាលខេត្ត ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមាន ក្នុងការិយាល័យ អង្គភាព និង ទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័នដែលប្រចាំនៅក្នុងក្រុងរបស់ខ្លួន ឬ ក្នុងករណីប្រធានការិយាល័យ ប្រធានអង្គភាព និង អ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី និង ភារកិច្ចរបស់ខ្លួន។ អភិបាលខេត្តត្រូវណែនាំដល់មន្ទីរ អង្គភាពខ្សែបណ្ដោយសាមីនៅថ្នាក់ខេត្ត ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មាធិការ ឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលក្រុងពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតករណីនេះជាបន្ទាន់ដើម្បីធ្វើសេចក្ដីរាយការណ៍ជូនមន្ត្រី ឬប្រធានស្ថាប័នសាមីដោះស្រាយស្របតាមនីតិវិធី
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្ដូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬ ប្រធានអង្គភាព ឬ អ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

**បញ្ជាក់ ៖**

✓ ដើម្បីធានាឱ្យអភិបាលក្រុងអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្ដីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និង ទីភ្នាក់ងារនានារបស់ក្រុង ស្ថាប័នដែលប្រចាំនៅក្រុងត្រូវ

ដាក់ជូនអភិបាលក្រុង ដើម្បីពិនិត្យនិង ផ្ដល់យោបល់។ ប្រសិនបើអភិបាលក្រុងឯកភាព អភិបាលក្រុងត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយប្រធានការិយាល័យ អង្គភាព និង អ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។

✓ ចំពោះសេចក្ដីរាយការណ៍ ក្រៅពីនេះរបស់ការិយាល័យ អង្គភាព និង ទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅក្រុងត្រូវចម្លងជូនសាលាក្រុង។

➢ ***របៀបរបបការងាររបស់គណៈអភិបាលក្រុង ៖*** ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន គណៈអភិបាលក្រុង អភិបាលក្រុង អភិបាលរងក្រុងត្រូវពិនិត្យ ពិចារណាលើចំណុចសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

- ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនអភិបាលក្រុងត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និង ការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និង ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងស្ថាប័ននានា ស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន និង ការងារដទៃទៀត ដែលខ្លួនយល់ឃើញថាចាំបាច់អភិបាលក្រុងត្រូវយកការងារទាំងនោះមកពិគ្រោះ ពិភាក្សាក្នុងគណៈអភិបាលក្រុងរបស់ខ្លួន ដោយឈរលើគោលការណ៍ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និង គោលការណ៍ណែនាំពីក្រុមប្រឹក្សាក្រុងរបស់ខ្លួន
- អភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះមុខ ក្រុមប្រឹក្សាក្រុង ទៅលើសកម្មភាពការងារទាំងអស់របស់គណៈអភិបាលក្រុងរបស់ខ្លួន។ អភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាក្រុងលើកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលក្រុងរបស់ខ្លួន
- ដើម្បីធានាឱ្យបាននូវគោលការណ៍ នៃការអនុវត្តការងារនេះគណៈអភិបាលក្រុង ត្រូវជួបជុំប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ ក្រៅពីការប្រជុំអឌ្ឍមាស និងការប្រជុំប្រចាំខែគណៈអភិបាលក្រុង អាចកោះប្រជុំតាមការចាំបាច់។ រៀងរាល់កិច្ចប្រជុំទាំងនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ
- គណៈអភិបាលក្រុងត្រូវប្រជុំពិភាក្សា ដើម្បីបែងចែកភារកិច្ចដល់ អភិបាលក្រុង និង អភិបាលរងក្រុង ហើយសុំការសម្រេចពីក្រុមប្រឹក្សាក្រុងរបស់ខ្លួន។ អភិបាលរងក្រុងដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលក្រុង

- អភិបាលក្រុង ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែង ការងារប្រចាំថ្ងៃ ដើម្បីអនុវត្ត សេចក្ដីសម្រេចនៃក្រុមប្រឹក្សាក្រុងរបស់ខ្លួន លើកលែងតែលិខិតបទដ្ឋាន ដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខា លើឯកសារលិខិតស្នាមរដ្ឋបាល ចាំបាច់មួយចំនួន ក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែក ជូនអភិបាលរងក្រុងនីមួយៗ។ ប៉ុន្តែអភិបាលក្រុងត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និង បែបបទនីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង
- អភិបាលក្រុងមានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយដែលប្រើប្រាស់អំណាចនេះមិនសមស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី។ ការប្រគល់ និងការដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខានេះ អភិបាលក្រុងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន។
- ក្នុងករណីអភិបាលក្រុងអវត្តមាន អភិបាលក្រុងត្រូវផ្ទេរសិទ្ធ ជាលាយលក្ខណ៍អក្សរជូនអភិបាលក្រុងមួយរូប ឱ្យទទួលជាអភិបាលក្រុងស្ដីទី។ ប្រសិនបើអភិបាលក្រុងអវត្តមានដោយពុំផ្ទេរសិទ្ធិអភិបាលរងក្រុងដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃប្រកាសតែងតាំងអភិបាលរង នៃគណៈអភិបាលក្រុង ត្រូវធ្វើជាអភិបាលក្រុងស្ដីទី។ ក្នុងករណីគណៈអភិបាលក្រុងស្ដីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកាដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូប ឱ្យទទួលជាអភិបាលក្រុងស្ដីទី និង ត្រូវធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្ដីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលក្រុងស្ដីទីត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលក្រុងនៅពេលដែលអភិបាលក្រុងមានអវត្តមានវិញ
- គណៈអភិបាលក្រុង ឬ អភិបាលក្រុង ឬ អភិបាលរងក្រុង ដែលបានសម្រេច ឬ ដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុងការសម្រេច ឬ សកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលក្រុង ឬ អភិបាលក្រុង ឬ អភិបាលរងក្រុងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬ សកម្មភាពខាងលើនេះ។

## ១.៣. កត្តាដែលជំរុញឱ្យមានការរៀបចំក្រុង

ការរៀបចំក្រុងមួយឱ្យល្អចាំបាច់ត្រូវតែមានការគិតគូរឱ្យបានហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយដូចនេះហើយទើបការរៀបចំក្រុងនីមួយៗត្រូវធ្វើដោយការផ្ចិតផ្ចង់ ពុំមែនធ្វើឡើងដោយភាពចៃដន្យនោះទេពោល គឺកើតឡើងដោយសារតែមានការជំរុញពីកត្តាផ្សេងៗជាច្រើនដូចជា ៖ កំណើនប្រជាជន កំណើនភ្ញៀវទេសចរជាតិ និង អន្តរជាតិ និងភាពក្រីក្រ ដែលត្រូវបកស្រាយតាមចំណុចមួយៗនៅខាងក្រោមនេះ ៖

### ១.៣.១. កំណើនប្រជាជន

ការកើនឡើងនៃចំនួនប្រជាជននៅតាមតំបន់ ឬ ទីក្រុងតែងតែកើតមានឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយវាក៏ជាមូលហេតុមួយដ៏សំខាន់ដែលចាំបាច់តម្រូវឱ្យមានការរៀបចំក្រុងសារជាថ្មីម្តងទៀត។ ជាទូទៅសមាសភាពនៃកំណើនប្រជាជន ក្នុងក្រុងមានកត្តា៣ សំខាន់ៗដូចជា កំណើនប្រ ជាជនតាមលក្ខណៈធម្មជាតិ កំណើនប្រជាជនដោយការធ្វើចំណាកស្រុកនៃប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទ និងកំណើនដោយសារតែមានការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដែលពីមុនតំបន់នោះជាទីជនបទ។[18] តួយ៉ាងកំណើនប្រជាជនក្នុងក្រុងតាមលក្ខណៈធម្មជាតិ បានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន រីឯកំណើនដោយសារមានការចំណាកស្រុករបស់ប្រជាជននៅជនបទ និងកំណើនដោយមានការបែងចែកក្រុងថ្មី ត្រឹមតែជាធាតុផ្សំបន្ទាប់បន្សំប៉ុណ្ណោះ។ កំណើនប្រជាជនបានបង្កឱ្យមានបញ្ហាមួយចំនួនដូចជា ៖

- **ការកកស្ទះចរាចរណ៍** ៖ គឺជាបញ្ហាដ៏ធំមួយដោយសារចំនួនប្រជាជនមានការកើនឡើង ដូចនេះតម្រូវការប្រើប្រាស់យានយន្តគ្រប់ប្រភេទ ក៏ត្រូវមានការកើនឡើង ដែលជាមូលហេតុបង្កឱ្យមានការស្ទះចរាចរណ៍ ព្រោះតម្រូវការនៃការប្រើប្រាស់ផ្លូវមានចំនួនច្រើន និងអ្នកប្រើប្រាស់ផ្លូវមួយចំនួនក៏មិនបានគោរពច្បាប់ចរាចរណ៍ ដោយពួកគាត់បើកប្រជែងគ្នាដើម្បីបានទៅមុខរៀងៗខ្លួន ដោយមិនខ្វល់ពីអ្នករួមដំណើរជាមួយនោះទេ។ ផ្លូវដែលមានការកកស្ទះភាគច្រើន ជាតំបន់ផ្សារ ឬ រោងចក្រជាដើម ដែលបង្កមកពីអាជីវកម្មមួយចំនួនគាត់បានប្រើប្រាស់ចិញ្ចើមផ្លូវធ្វើជាការលក់ដូរ។ តួយ៉ាងការកកស្ទះចរាចរណ៍ ជាបញ្ហាដ៏ធំមួយដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់សុខភាពផ្លូវចិត្តខាតពេលវេលា និង ខាតបង់លុយកាក់ ដោយសារនៅពេលស្ទះចរាចរណ៍ម្តងៗអ្នកបើកបរលើដងផ្លូវត្រូវការបញ្ឆេះឡាន ម៉ូតូ កង់បីទុកចោលទម្រាំតែបានចេញដំណើរ ដែលនោះធ្វើឱ្យមានការខាតបង់ក្នុងការចំណាយទៅលើប្រេងសាំង ឬ ម៉ាសូត ដែលពួកគាត់បានបញ្ឆេះចោលនៅពេលស្ទះចរាចរណ៍ ហើយវាក៏បង្កឱ្យមានការបំពុលបរិស្ថានបន្ថែមទៀតផងដែរ។
- **ការរីករាលដាលនៃសំណង់អនាធិបតេយ្យ** ៖ តំបន់អនាធិបតេយ្យគឺជាតំបន់ដែលមានប្រជាជនរស់នៅភាគច្រើនសម្បូរទៅដោយលំនៅដ្ឋាន ដែលមិនមានគុណភាព និង សាងសង់នៅតំបន់ខុសច្បាប់ ដូចជានៅលើប្រឡាយ ឬ អូរជាដើម ដែលភាគច្រើនរស់នៅដោយប្រជាជនក្រីក្រ ឬ ប្រជាជនដែលចំណាកស្រុកពីជនបទ។ មួយវិញទៀតការកើនឡើងនៅសំណង់អនាធិបតេយ្យនេះក៏ធ្វើឱ្យមានផលប៉ះពាល់ដល់សោភ័ណភាពទីក្រុងផងដែរ។
- **កង្វះខាតអគ្គសនី** ៖ ដោយសារតែប្រជាជនមានចំនួនកើនឡើងជាលំដាប់ តម្រូវការនៃការប្រើប្រាស់ថាមពលអគ្គិសនី ក៏ត្រូវមានការកើនឡើងដូចគ្នាជាលំដាប់នឹងបញ្ហា ឬ តម្រូវការផ្សេងៗជាច្រើនទៀត។

[18] បណ្ឌិត អ៊ុន សកក្កដា, នីតិនគរូបនីយកម្ម(២០១៩-២០២០), ទំព័រ៥

ដូច្នេះដើម្បីដោះស្រាយ បញ្ហាទាំងអស់នេះបាន គឺទាមទារឱ្យទីក្រុងត្រូវមានការអភិវឌ្ឍរៀបចំកែប្រែទីក្រុង ដើម្បីឱ្យមានសណ្ដាប់ធ្នាប់របៀបរៀបរយ និង អនាម័យ ដើម្បីបំពេញនូវតម្រូវការរបស់ប្រជាជនក្នុងក្រុង ព្រោះកាលណាប្រជាជននៅតែកើនឡើង នោះតម្រូវការក៏នៅតែមានការកើនឡើងជាមួយគ្នាដែរ។

### ១.៣.២. កំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ

ក្រុងព្រះសីហនុ គឺជាទីក្រុងមួយដែលមានការអភិវឌ្ឍជឿនលឿន ថែមទាំងមានកន្លែងកម្សាន្តជាច្រើន ដែលអាចទាក់ទាញភ្ញៀវទេសចរជាតិ និង អន្តរជាតិបានយ៉ាងច្រើន ក៏ព្រោះតែមានសោភ័ណភាពស្រស់ស្អាត នៅតាមដងផ្លូវ តាមឆ្នេរសមុទ្រ ម្ហូបអាហារស្រស់ៗមានភាពទាក់ទាញ។ ទាំងក្នុងអំឡុងពេលថ្ងៃឈប់សម្រាក និង ពិធីបុណ្យផ្សេងៗ។ ម្យ៉ាងវិញទៀត ក្រុងព្រះសីហនុមានការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង ទទួលបានការរីកចម្រើនផ្នែកសេដ្ឋកិច្ចលើគ្រប់វិស័យព្រមទាំងមានសក្ដានុពលផ្នែកទេសចរណ៍បន្ថែមទៀតដែរ។ ក្នុងនោះផងដែរក្រុងព្រះសីហនុក៏មានកន្លែងកម្សាន្តជាច្រើន ដូចជា ឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ ឆ្នេរឯករាជ្យ ឆ្នេរសុខា កោះថ្មី រមណីយដ្ឋានទឹកជ្រោះក្បាលឆាយ និង មានកោះស្អាតៗមួយចំនួនទៀត ដែលជាកត្តាជំរុញឱ្យមានទាំងភ្ញៀវទេសចរជាតិ និង អន្តរជាតិមកទស្សនាយ៉ាងច្រើនកុះករ ជាពិសេសនៅថ្ងៃឈប់សម្រាកផ្សេងៗ។

### ១.៣.៣. ភាពក្រីក្រ

យើងអាចកំណត់អំពីស្ថានភាពក្រីក្រ បានដោយអាចឃើញពីការលំបាក កម្រិតជីវភាព និង កង្វះខាតក្នុងគ្រួសារ ដូចជា ចំណីអាហារ លំនៅដ្ឋាន ការងារ ធនធាន អគ្គិសនី អនាម័យសុខមាលភាពសង្គម។ ចំពោះការសម្គាល់ពីភាពក្រីក្រ ត្រូវបានសង្កត់ធ្ងន់លើប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា ៖ ការកើនឡើងករណីឧក្រិដ្ឋកម្ម អំពើហិង្សាក្នុងគ្រួសារ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យម ត្រូវបានសន្មតថាជាជនក្រីក្រ។ បើយើងប្រៀបធៀបភាពក្រីក្រនៅតាមជនបទ និង ភាពក្រីក្រនៅទីក្រុងឃើញថាមានលក្ខណៈខុសគ្នា ដោយហេតុថានៅទីក្រុងត្រូវមានការចំណាយខ្ពស់ជាងនៅតាមជនបទ ហើយអ្នករស់នៅតាមជនបទ អាចមានឱកាសស្វែងរកការចិញ្ចឹមជីវិត តាមរយៈការទទួលអំណោយសប្បុរសជន ភោគផលពីធម្មជាតិច្រើនជាងអ្នកនៅទីក្រុង។ តាមរយៈនេះយើងអាចសង្កេតឃើញថា អ្នកក្រនៅទីក្រុងមានស្ថានភាពលំបាកជាងអ្នកក្រនៅជនបទ។[19] មួយវិញទៀតភាពក្រីក្រនេះបាន ធ្វើឱ្យមានបញ្ហាជាច្រើនទាក់ទងនឹងសណ្ដាប់ធ្នាប់ និងសោភ័ណភាពផងដែរ ដោយសារតែប្រជាជនក្រីក្រភាគច្រើន គ្មានទីលំនៅស្នាក់នៅសមរម្យ ដែលអ្នកខ្លះត្រូវស្នាក់ឬសម្រាកនៅតាមចិញ្ចើមផ្លូវ ឬសួនច្បារជាដើម។ ម្យ៉ាងវិញទៀតប្រជាពលរដ្ឋមួយចំនួនត្រូវដើរសុំទាននៅតាមស្តុប ទីវត្តអារាម ឬតាមផ្ទះ សាលារៀនជាដើម ដើម្បីយកប្រាក់មកទិញអាហារហូបចុកសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ។

[19] បណ្ឌិត អ៊ុន សកក្កដា, នីតិនគរូបនីយកម្ម(២០១៩-២០២០), ទំព័រ៧

# ជំពូកទី២
# ការរៀបចំសោភ័ណភាព
# និងសណ្ដាប់ធ្នាប់ក្រុងព្រះសីហនុ

# ជំពូកទី២

# ការរៀបចំសោភ័ណភាព និង សណ្តាប់ធ្នាប់ក្រុងព្រះសីហនុ

ក្រុងព្រះសីហនុ ជាទីក្រុងមួយដែលមានសក្តានុពលខ្លាំងគ្រប់វិស័យ ដូច្នេះក្នុងការរៀបចំទីក្រុងមួយឱ្យមានសោភ័ណភាពល្អ យើងត្រូវរៀបចំក្រុងជាលក្ខណៈពិធីការដែលត្រូវបានសង្កេតឃើញឈរក្រោមសសរស្តម្ភចំនួន ៥ គឺ៖ **ផលិតភាព និរន្តភាព ភាពដែលអាចរស់នៅបាន ភាពជាអ្នកដឹកនាំ និង ការរចនា** ដ៏ល្អប្រសើរ។[20]

តួយ៉ាងការកសាងផ្លូវក្រុងនិងហេដ្ឋារចនាសម្ព័ន្ធក្រុងព្រះសីហនុត្រូវបានអនុវត្តដោយរក្សានូវសក្តានុពលធម្មជាតិ និង បរិស្ថានដូចជា តំបន់ឆ្នេរសមុទ្រ ទេសភាពនគរូបនីយកម្ម ជាពិសេសត្រូវបានតភ្ជាប់សក្តានុពលតំបន់ឆ្នេរឱ្យមានទំនាក់ទំនងគ្នា តាមរយៈការស្ថាបនាផ្លូវ និង ស្ពាន។ ទាំងអស់នេះបានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់អំពីការខិតខំប្រឹងប្រែងក្នុងការរៀបចំ និង ការកែលម្អហេដ្ឋារចនាសម្ព័ន្ធនានាបន្ថែមទៀត រួមមាន៖ ផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ និង ទីកន្លែងកម្សាន្តផ្សេងៗ។ មួយវិញទៀតការរៀបចំក្រុងព្រះសីហនុ មិនត្រឹមតែផ្តោតទៅលើវិស័យទេសចរណ៍តែមួយមុខទេថែមទាំងមានគោលបំណងនៃការរៀបចំក្រុងព្រះសីហនុឱ្យមានសណ្តាប់ធ្នាប់ និង របៀបរៀបរយមានជាច្រើនដូចខាងក្រោម ៖

- **ការលើកកម្ពស់ សកម្មភាពសេដ្ឋកិច្ច** ៖ ការរៀបចំក្រុង ឱ្យកាន់តែមានភាពទាក់ទាញ ដែលប្រកបដោយផាសុកភាព និង សុវត្ថិភាព បង្កើតឱ្យមានការលើកទឹកចិត្ត ក្នុងការប្រកបអាជីវកម្មផ្សេងៗ បង្កើនសម្រស់លើដងផ្លូវ រមណីយដ្ឋានធម្មជាតិ គឺបានទាក់ទាញភ្ញៀវទេសចរ គ្រប់ជាតិសាសន៍ចូលមកទស្សនា។ មួយវិញទៀតមានការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ដើម្បីឱ្យមានការធ្វើដំណើរដោយសុវត្ថិភាពពេលទៅប្រកបការងារ។
- **ផ្តល់ផាសុកភាព និង បង្កើនសុខុមាលភាពនៅក្នុងក្រុង** ៖ ការធ្វើឱ្យមានផាសុកភាព ភាពសុខសាន្តនៅក្នុងទីក្រុង បានធ្វើឱ្យមានភាពងាយស្រួលក្នុងការដើរហើរ ឈរអង្គុយ និង សម្រាកកម្សាន្ត លំហែដែលមិនត្រូវបានរំខានដោយភ្លៀង ខ្យល់ សំឡេង សំរាម កម្តៅ ការបំពុលបរិស្ថាន និង ចរាចរណ៍អ្វីឡើយ។ ការធ្វើបែបនេះគ្មានភាពចលាចល ក៏ដូចជាមានគោលបំណងបម្រើដល់ប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ទាំងអនាម័យ និង ការរស់នៅរបស់ប្រជាជន តាមតំបន់ ហើយក៏អាចធានាបាននូវសុវត្ថិភាពគ្រប់ផ្នែកទាំងអស់នៅក្នុងក្រុងដោយផ្អែកលើគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

ជាការពិតណាស់ការអភិវឌ្ឍ និង រៀបចំក្រុងនីមួយៗតម្រូវឱ្យមានទំនួលខុសត្រូវខ្ពស់ ព្រមទាំងធានាឱ្យមានអ្នកការពារ និង តាមដានថែរក្សាជាប្រចាំ។ បរិស្ថានរបស់ទីក្រុង និង សហគមន៍ ត្រូវរក្សានៅក្នុងលក្ខខណ្ឌការកែប្រែឱ្យបានប្រសើរ ទើបអាចបំពេញបានតម្រូវការជាក់លាក់របស់មនុស្សក្នុងក្រុងនេះ ស្របពេលជាមួយគ្នា

[20] បណ្ឌិត អ៊ុន សកក្កដា, នីតិនគរូបនីយកម្ម(២០១៩-២០២០), ទំព័រទី១៣

នេះដែរ ត្រូវធ្វើការថ្លឹងថ្លែងអំពីផលប៉ះពាល់ និង គុណប្រយោជន៍ដែលទទួលបានផងដែរ។ ក្នុងន័យនេះ គឺត្រូវធានាថារាល់ការរចនារៀបចំកន្លែងនីមួយៗ គឺត្រូវមានការធ្វើប្រតិបត្តិ ការថែរក្សា ជាប្រចាំ ជាពិសេសនៅពេលមានគ្រោះអាសន្ន។[21] ម្យ៉ាងវិញទៀតត្រូវមានការលើកទឹកចិត្តសម្រាប់មន្ត្រីមានសមត្ថកិច្ច ដែលបានអនុវត្តទៅតាមគោលការណ៍បានយ៉ាងល្អខ្ជាប់ខ្ជួន និង ត្រឹមត្រូវទៅតាមច្បាប់។

## **២.១. ការរៀបចំក្រុងព្រះសីហនុ**

ដោយយើងបានដឹងថា ក្រុងព្រះសីហនុកំពុងក្លាយជាគោលដៅទេសចរណ៍ដ៏មានសក្តានុពល ដែលបានទាក់ទាញភ្ញៀវទេសចរជាតិ និង អន្តរជាតិយ៉ាងច្រើនកុះករ ជាហេតុដែលញ៉ាំងឱ្យរដ្ឋបាលក្រុងព្រះសីហនុដោយមានការសហការផ្ទាល់ពីមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សំណង់ក្រុងព្រះសីហនុ និង ក្រសួងស្ថាប័នទាំងឡាយដែលមានសមត្ថកិច្ច បាននឹងកំពុងព្យាយាម រៀបចំគ្រប់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជាកត្តាដែលផ្តល់ភាពងាយស្រួល ដល់អ្នកដំណើរជិតឆ្ងាយ។

### **២.១.១. ការរៀបចំសោភ័ណភាពក្រុងព្រះសីហនុ**

ក្រុងព្រះសីហនុ គឺជាតំបន់អភិវឌ្ឍន៍ដែលបានទាក់ទាញភ្ញៀវទេសចរជាតិ និង អន្តរជាតិមកទស្សនកិច្ចជារឿយៗ ដែលជាកត្តាជំរុញឱ្យមានការរៀបចំក្រុងប្រកបដោយគុណភាព ជាពិសេសសោភ័ណភាព ដែលជាផ្ទាំងទស្សនីយភាពមួយដែលអាចលម្អក្រុងឱ្យកាន់តែមានភាពទាក់ទាញ និងស្រស់ស្អាតជាលំដាប់។ ជាក់ស្តែងបើយោងទៅតាមវចនា**សម្តេចព្រះសង្ឃរាជ ជួន ណាត** ចំពោះពាក្យ សោភ័ណភាពនេះ គឺសំដៅទៅលើ ភាពល្អហ្មត់ហ្មង។[22]

សោភ័ណភាពជាផ្នែកមួយដ៏សំខាន់ ដែលអាចជួយជំរុញឱ្យមានការរៀបចំក្រុងកាន់តែល្អប្រសើរ និងប្រកបដោយភាពល្អ ហ្មត់ហ្មង។ ការរស់នៅរបស់ប្រជាជន គឺអាស្រ័យទៅលើសោភ័ណភាពរបស់ក្រុង នៅក្នុងការសម្រួលដល់ការធ្វើដំណើរដែលពោរពេញទៅដោយផាសុកភាព និង សុវត្ថិភាព ហើយសោភ័ណភាព ត្រូវបានបែងចែកជាពីរ ក្នុងនោះមាន **សោភ័ណភាពពេលថ្ងៃ និង សោភ័ណភាពពេលយប់។**

ជាពិសេសទៅទៀតនោះចំពោះការរៀបចំក្រុងព្រះសីហនុបានធ្វើឡើងអមជាមួយសោភ័ណភាពពេលថ្ងៃ និង ពេលយប់ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកដំណើរ និង ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងផ្ទាល់តែម្តង។

#### **២.១.១.១. សោភ័ណភាពពេលថ្ងៃ**

សោភ័ណភាពពេលថ្ងៃ គឺផ្តោតសំខាន់ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធសព្វគ្រប់បែបយ៉ាង ដែលរួមមាន ផ្លូវ ស្ពាន សាលារៀន ចិញ្ចើមផ្លូវ សំណង់អគារតូចធំគ្រប់ប្រភេទ សួនច្បារសាធារណៈ និងប្រព័ន្ធសុវត្ថិភាព

[21] បណ្ឌិត អ៊ុន សកក្កដា, នីតិនគរូបនីយកម្ម(២០១៩-២០២០), ទំព័រទី១៧

[22] សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ

ចរាចរណ៍ផ្សេងៗដែលមានដូចជា ភ្លើងសញ្ញា, ស្លាកសញ្ញា, និង គំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនូវគ្រប់ប្រភេទយានយន្តទាំងអស់ បូករួមទាំងអ្នកថ្មើរជើងផង ប្រកបដោយសុវត្ថិភាព សណ្តាប់ធ្នាប់ និង របៀបរៀបរយល្អ។[23]

ជាទូទៅសោភ័ណភាពពេលថ្ងៃបានជួយសម្រួលដល់ការលំបាកជាច្រើនរបស់ប្រជាពលរដ្ឋ ជាពិសេសការធ្វើដំណើរពីកន្លែងមួយទៅកាន់កន្លែងមួយទៀត។ ជាការពិតណាស់ការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធបានក្លាយជាកត្តាចម្បងមួយក្នុងការបង្កើនសោភ័ណភាព និង សណ្តាប់ធ្នាប់ល្អនៅក្នុងទីក្រុងថែមមួយកម្រិតទៀតផងដែរ។

ដើម្បីធានានូវបញ្ហាគ្រោះថ្នាក់ចរាចរណ៍មិនឱ្យកើតមានឡើង នៅតាមដងផ្លូវ ឬ កន្លែងមួយចំនួនទៀត អាជ្ញាធរបានខិតខំបំពាក់នូវប្រព័ន្ធសុវត្ថិភាពចរាចរណ៍ដូចខាងក្រោម៖

- **អំពូលភ្លើង ៖** ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបំពាក់អំពូលភ្លើងអគ្គិសនី គឺអាជ្ញាធរបានដាក់អំពូលភ្លើងខ្សែតាមបង្គោលភ្លើងទាំងអស់ និង ដាក់បំពាក់តាមដងផ្លូវ ក្នុងការជួយសម្រួលឱ្យមានភាពងាយស្រួលដល់ការបើកបររបស់អ្នកប្រើប្រាស់លើដងផ្លូវទាំងឡាយ ហើយជាពិសេសទៅទៀតនោះអាចបង្ការមិនឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើតមានជាយថាហេតុ ព្រោះប្រសិនបើកង្វះនូវពន្លឺដោយពឹងផ្អែកតែទៅលើភ្លើងយានយន្តដែលមានគឺមិនគ្រប់គ្រាន់ឡើយ វាអាចបណ្តាលឱ្យមានភាពស្រពិចស្រពិលក្នុងការបើកបរនៅលើតាមដងផ្លូវផងដែរ។
- **ភ្លើងសញ្ញាចរាចរណ៍ ៖** ក្នុងការរៀបចំភ្លើងសញ្ញាចរាចរណ៍ គឺត្រូវតែមានការប្រុងប្រយ័ត្នដែលអាចជួយសម្រួលឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការធ្វើដំណើរ។ មួយវិញទៀតគួរតែមានការតម្លើងភ្លើងចរាចរណ៍បន្ថែមនៅចំណុចប្រសព្វ ឬ ការកែសម្រួលភ្លើងសញ្ញាចរាចរណ៍ទាំងឡាយណាដែលខូច ឬមានបញ្ហាបច្ចេកទេសណាមួយដែលជាហេតុបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍យ៉ាងងាយ។
- **ស្លាកសញ្ញាចរាចរណ៍ ៖** ត្រូវតែមានការតម្លើងស្លាកសញ្ញាចរាចរណ៍ទៅតាមប្រភេទ ដែលស្របទៅតាមតំបន់ផ្សេងៗ ដោយមានចំណុចមួយចំនួនដូចជា នៅចំណុចផ្លូវកោង ផ្លូវបត់ ចំណុចផ្លូវប្រសព្វ ផ្លូវដែលកំពុងតែមានការដ្ឋានសាងសង់ និង ផ្លូវរថភ្លើងជាដើម។ ចំពោះការតម្លើងនូវស្លាកសញ្ញាចរាចរណ៍នេះដូចជាការផ្តល់ដំណឹងជូន និង ជាការដាស់តឿនស្មារតី របស់អ្នកបើកបរឱ្យបង្កើនការប្រុងប្រយ័ត្ន និង ធ្វើដំណើរដោយសុវត្ថិភាព។

### ២.១.១.២. សោភ័ណភាពពេលយប់

សោភ័ណភាពពេលយប់ គឺសំដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និង តាមដងវិថីនានាក្នុងទីក្រុង ជាពិសេសការបំពាក់នូវភ្លើងបំភ្លឺចម្រុះពេលរាត្រីនៅតាមសួនច្បារសាធារណៈនៅក្នុងក្រុង។

---

[23] បណ្ឌិត អ៊ុន សកក្កដា, នីតិនគរូបនីយកម្ម(២០១៩-២០២០), ទំព័រ១

រាល់ហេដ្ឋារចនាសម្ព័ន្ធទាំងអស់ ត្រូវការភ្លើងបំភ្លឺដើម្បីបង្កើនសម្រស់ និងសុវត្ថិភាពតាមដងវិថី។ តួយ៉ាង ខណៈពេលដែលព្រះអាទិត្យចាប់អស្តង្គត ភពផែនដីនឹងចុះងងឹតសូន្យសុង ពិបាកនឹងកំណត់គោលដៅ។ ដូច្នេះ ដើម្បីសម្រួលបញ្ហានេះនៅតាមតំបន់នីមួយៗ គឺគេបានរកវិធីសាស្ត្រយ៉ាងណាដើម្បីបំភ្លឺតំបន់របស់ខ្លួន។ បច្ចុប្បន្ន នេះគេបានបំពាក់ភ្លើងអគ្គិសនី ដើម្បីបំភ្លឺនៅតាមទីកន្លែងនីមួយៗ ដើម្បីភាពស្រស់ស្អាតនៅតាមផ្លូវសាធារណៈ គេបានបំពាក់នូវភ្លើងបំភ្លឺចម្រុះពណ៌ថែមទៀតផង។ ទិដ្ឋភាពនាពេលរាត្រីនៅក្រុងព្រះសីហនុ គឺមានភាពទាក់ទាញយ៉ាងខ្លាំង និង មានការចាប់អារម្មណ៍ពីសំណាក់មហាជនដែលជាភ្ញៀវទេសចរជាតិ និង អន្តរជាតិជាច្រើន ដោយមូលហេតុថាមានការបំពាក់ភ្លើងពណ៌ចម្រុះបំភ្លឺតាមដងផ្លូវគ្រប់គ្រាន់។ ជាពិសេសទៅទៀតនោះ ចំពោះការបំពាក់ភ្លើងពណ៌នៅតាមដងផ្លូវមានដូចជា នៅតាមដងផ្លូវទៅឆ្នេរសមុទ្រ តាមសួនច្បារក្នុងក្រុង សំខាន់បំផុតនោះគឺនៅត្រង់ចំណុចរង្វង់មូលតោពីរដែលជារូបតំណាងឱ្យខេត្តព្រះសីហនុទាំងមូល ខណៈដែលមានភ្លើងចម្រុះលម្អបែបនេះ វាបានបង្កើននូវសម្រស់ស្រស់ស្អាតមួយកម្រិតថែមទៀត និង កន្លែងមួយចំនួនផ្សេងទៀត ក៏មានការបំពាក់នូវភ្លើងបំភ្លឺចម្រុះពណ៌ ដើម្បីលម្អសោភ័ណភាពនាពេលរាត្រីនៅក្នុងក្រុងផងដែរ។

### ២.១.២. ការរៀបចំសណ្តាប់ធ្នាប់

ដើម្បីឱ្យទីក្រុងមួយមើលទៅប្រកបដោយសោភ័ណភាពល្អប្រសើរ អាស្រ័យទៅលើសណ្តាប់ធ្នាប់តាមទីសាធារណៈមានការរៀបចំឱ្យមានរបៀបរៀបរយផងដែរ។ ការរៀបចំក្រុងត្រូវប្រកបដោយភាពស្រស់ស្អាត ហើយការរក្សាសណ្តាប់ធ្នាប់នេះធ្វើឱ្យទីក្រុងមាននូវរបៀបរៀបរយល្អ និងគ្មានភាពរញ៉េរញ៉ៃ។ មួយវិញទៀតមន្ត្រីមានសមត្ថកិច្ចបានខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋក្នុងពិធីបុណ្យផ្សេងៗថែមទៀតផង។

សណ្តាប់ធ្នាប់ត្រូវបានបែងចែកជា បួន ចំណុចសំខាន់ៗមានដូចខាងក្រោម៖

#### ២.១.២.១. សន្តិសុខ

ដើម្បីធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និង ទីក្រុងមួយទាំងមូលឱ្យបាននូវសណ្តាប់ធ្នាប់ល្អ គឺត្រូវធានាឱ្យបាននូវ សន្តិសុខ សុវត្ថិភាពដែលជាសេចក្តីសុខ និង គ្មានភាពចលាចលផ្សេងៗកើតឡើង។ ដើម្បីចូលរួមចំណែកលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឱ្យស្របតាមគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ឱ្យការរស់នៅប្រកបសន្តិភាពនោះ រាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធនានា ជាពិសេសដោយមានការចង្អុលបង្ហាញពីគណៈបញ្ជាការ បានធ្វើការឯកភាពគ្នាទើបរដ្ឋបាលក្រុងព្រះសីហនុ អាចធ្វើការបង្ក្រាបសកម្មភាពបទល្មើសផ្សេងៗដូចជា ការចែកចាយ គ្រឿងញៀន ចោរលួច ឆក់ ប្លន់ ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ ក្មេងទំនើង ការល្មើសច្បាប់ចរាចរណ៍ផ្លូវគោក និង បទល្មើសផ្សេងៗទៀតជាច្រើន។ មួយវិញទៀតក៏មានការពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន, ការបង្កើតការិយាល័យសម្របសម្រួលច្រកចេញចូលតែមួយ និង

ការជួយបណ្តុះបណ្តាលធនធានមន្ត្រីនគរបាលកម្ពុជាព្រមទាំងបំពាក់សម្ភារៈទំនើបដើម្បីជាកត្តាពង្រឹងដល់សុខសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ នៅក្រុងព្រះសីហនុផងដែរ។[24]

ជាពិសេសទៅទៀតនោះរាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ដើម្បីធានាការពារសុខសុវត្ថិភាព សន្តិសុខ និង សណ្តាប់ធ្នាប់ ក្នុងភូមិ ឃុំរបស់ប្រជាពលរដ្ឋឱ្យមានភាពរីករាយក្នុងការរស់នៅមានសេចក្តីសុខ។ លើសពីនេះទៅទៀត ក្នុងការការពារភូមិ ឃុំ គឺគ្រាន់តែជាការរក្សាការពារទប់ស្កាត់មិនឱ្យកើតមានអសន្តិសុខទៅលើទ្រព្យសម្បត្តិ របស់របរផ្ទាល់ខ្លួន ដែលកើតចេញពីកម្លាំងញើសឈាមរបស់ប្រជាជន និង ម្យ៉ាងវិញទៀត ត្រូវធ្វើការគិតគូរ ហើយផ្តោតសំខាន់ទៅលើសុខភាពអនាម័យ សុខុមាលភាពរបស់ប្រជាពលរដ្ឋផងដែរ។ តួយ៉ាងការការពារសន្តិសុខមិនបានផ្តោតសំខាន់ទៅលើបរិបទសង្គមតែមួយមុខនោះទេ ប៉ុន្តែសន្តិសុខបានសំដៅលើសុវត្ថិភាពបីសំខាន់ៗរួមមាន៖

- **សុវត្ថិភាពបុគ្គល ៖** ការការពារសុខសុវត្ថិភាពរបស់បុគ្គល គឺសំដៅទៅលើទីកន្លែង ឬ តំបន់ទាំងឡាយណាដែលមានមនុស្សរស់នៅប្រកបដោយសេចក្តីសុខផ្លូវកាយ ឬ សុវត្ថិភាពរូបរាងកាយរបស់បុគ្គលត្រូវបានការការពារដែលសមរម្យមួយ និង ល្អប្រសើរ។ ដើម្បីជៀសវាងកុំឱ្យមានការប៉ះពាល់ដល់រូបរាងកាយរបស់ប្រជាពលរដ្ឋដោយកត្តាមួយចំនួនដូចជា អំពើហិង្សា ក្មេងទំនើង និង គ្រោះថ្នាក់ចរាចរណ៍ដែលបង្កដល់ការព្រួយបារម្ភយ៉ាងខ្លាំងពីសំណាក់ប្រជាជនរស់នៅតាមតំបន់។
- **សុវត្ថិភាពសម្ភារៈ ៖** ប្រជាជនគ្រប់រូបតែងតែស្រឡាញ់ និង ការពារទ្រព្យសម្បត្តិ សម្ភារៈផ្ទាល់ខ្លួនរបស់ពួកគាត់ណាស់ព្រោះវាជារបស់ចាំបាច់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ដូចនេះរាល់សម្ភារៈផ្ទាល់ខ្លួនទាំងឡាយ គឺពួកគេមិនចង់ឱ្យមានការបំពានពីជនណាម្នាក់ឡើយ។ បើក្នុងករណីខ្លះមិនអាចធ្វើការការពារទ្រព្យសម្បត្តិដោយខ្លួនឯងបានទេ ដោយសារតែមានការគំរាមកំហែងដល់អាយុជីវិត ដូច្នេះពួកគេបានធ្វើការស្នើសុំជំនួយពីមន្ត្រីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទទួលបានការជួយសង្គ្រោះ។ ដើម្បីធានាឱ្យក្រុងមួយមានសន្តិសុខ សុវត្ថិភាពពេញលេញល្អ ក្នុងការថែរក្សាទ្រព្យសម្បត្តិ ឬ សម្ភារៈផ្សេងៗ លុះត្រាតែនៅក្នុងមូលដ្ឋាននោះគ្មានសកម្មភាពនៃការប្រព្រឹត្តិបទល្មើសផ្សេងៗដូចជា៖
  - **គ្មានសកម្មភាព ឆក់ ប្លន់ និង ការចាប់ជំរិតគ្រប់ប្រភេទ** ៖ ទាំងនេះសំដៅទៅលើការគ្មានការគំរាមកំហែងយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួនដោយពុំមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិឡើយ ឬ ជាអំពើដែលអាចបណ្តាលឱ្យម្ចាស់ទ្រព្យត្រូវទទួលរងនូវសកម្មភាពនៃអំពើរំលោភបំពាន។

[24] នគរបាលជាតិកម្ពុជា និងក្រសួងសន្តិសុខចិន ជួបពិភាក្សាគ្នាជុំវិញ បញ្ហាសន្តិសុខនៅខេត្តព្រះសីហនុ - ក្រសួងព័ត៌មាន (information.gov.kh) (ចូលទស្សនាចុងក្រោយថ្ងៃទី២៧ មិថុនា ២០២១)

- **គ្មានសកម្មភាពនៃការប្រព្រឹត្តិអំពើជួញដូរ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់** ៖ ក្នុងករណីនេះការប្រើប្រាស់គ្រឿងញៀន ជាបញ្ហាមួយដែលបង្កដល់អសន្តិសុខសង្គម ឬ បង្កចលាចលដល់សង្គម ជាការពិតបុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀននេះតែងតែមានតម្រូវការថវិកាច្រើនក្នុងការទិញ និង លក់នូវសារធាតុញៀនទាំងឡាយ។
- **គ្មានការប្រព្រឹត្តល្បែងស៊ីសងខុសច្បាប់** ៖ ការលេងល្បែងស៊ីសង ជាអំពើខុសច្បាប់ដែលប្រជាជនមួយចំនួនមិនគួរយកខ្លួនទៅបៀតបៀន ដោយសារតែការលេងល្បែងនេះ តែងតែមានការចាញ់ ឈ្នះ ឬ អាចឈានទៅដល់ការភ្នាល់គ្នាដោយការដាក់ប្រាក់។ ដូចនេះប្រសិនបើពួកគាត់ដើរដល់ផ្លូវទាល់ លេងល្បែងចាញ់ គាត់អាចគិតធ្វើរឿងអ្វីដែលមិនល្អ ដោយសម្លឹងឃើញទ្រព្យសម្បត្តិអ្នកដទៃ និង មានគំនិតចង់បានដែលអាចឈានដល់ការប្រព្រឹត្តបទល្មើសផ្សេងៗ ដើម្បីឱ្យពួកគាត់អាចយកលុយទៅស្រង់ដើមបាន។

➢ ***សុវត្ថិភាពចំណីអាហារ*** ៖ ការទទួលទានអាហារដែលល្អត្រឹមត្រូវ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់រាងកាយរបស់មនុស្សគ្រប់រូប ប្រសិនបើការបរិភោគអាហាររបស់យើងមិនបានពេញលេញ និង អាហារដែលគ្មានគុណភាពល្អ ឬ ការប្រើប្រាស់បច្ចេកទេសផលិតមិនត្រឹមត្រូវតាមស្តង់ដារ វាអាចជះផលអាក្រក់ដល់សុខភាព។ ដូច្នេះរាល់អាហារដែលដាក់លក់នៅតាមផ្សារត្រូវមានការត្រួតពិនិត្យគុណភាពក៏ដូចជាសុពលភាពរបស់មុខទំនិញនីមួយៗឱ្យបានជាក់លាក់។ មួយវិញទៀតក្នុងនាមជាប្រជាជនធម្មតា គឺមិនអាចមើលដឹងពីសមាសភាពផ្សំណាដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពរបស់យើងនោះទេ ដែលតម្រូវឱ្យវាជាតួនាទីរបស់មន្ត្រីជំនាញក្នុងការពិនិត្យមើលអនាម័យចំណីអាហារដែលជា សមត្ថកិច្ចពាក់ព័ន្ធ និង សមត្ថកិច្ចរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ឬ ស្ថាប័នឯកទេសផ្សេងៗ។[25] ការកំណត់នីតិវិធី និង វិធានការដែលធានាថាម្ហូបអាហារ ដែលបាននាំចូលមានភាពអនុលោមស្របទៅតាមលក្ខខណ្ឌតម្រូវស្តីពីគុណភាព សុវត្ថិភាពម្ហូបអាហារ និង ភាពសមស្របសម្រាប់ការបរិភោគរបស់មនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[26]

**២.១.២.២. ភាពស្ងប់ស្ងាត់**

ភាពស្ងប់ស្ងាត់ គឺសំដៅទៅលើទីតាំងមួយដែលមិនមានការបំពុលដោយសំឡេង។ ស្របពេលជាមួយគ្នានេះ ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានភាពស្ងប់ស្ងាត់ អាជ្ញាធរដែលមានសមត្ថកិច្ច គឺត្រូវមានការហាមឃាត់មិនឱ្យសាងសង់ រោងចក្រ ឬ សហគ្រាស ដែលមានលំនៅដ្ឋានជិតប្រជាពលរដ្ឋ សាលារៀន និង មន្ទីរពេទ្យជាដើម ព្រោះវាបានបង្កឱ្យមានការរំខានដល់ប្រជាពលរដ្ឋ។

---

[25] អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ នាំចូលដើម្បីសម្រួលពាណិជ្ជកម្ម និង ពង្រឹងភាពប្រកួតប្រជែងកម្ពុជា, មាត្រា២

[26] ប្រកាសលេខ ២៦៣ អ.គបង.ប្រក ស្តីពីការកំណត់នីតិវិធីនៃការនាំចូលម្ហូបអាហារ, ប្រការ២

ជាការពិតណាស់ទោះបីរោងចក្រ និង សិប្បកម្មនូវតែបន្តកើនឡើងក៏ពិតមែន តែដើម្បីដំណើរការបាន លុះត្រាទទួលបានការអនុញ្ញាតត្រឹមត្រូវ ដោយត្រួតពិនិត្យទៅលើទីតាំងរោងចក្រ។ ជាក់ស្តែងរោងចក្រនីមួយៗ ត្រូវស្ថិតនៅទីជនបទ ឬ តំបន់ដាច់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ និង តំបន់រក្សាទុកការពារ។ ដូចនេះបានជានៅក្នុងទីប្រជុំជនមិនទាន់មានរោងចក្រផ្សេងៗនៅឡើយ ក៏ព្រោះតែវាអាចបណ្តាលឱ្យរំខានដល់ប្រជាជនក្នុងក្រុង។ យ៉ាងណាមិញ អ្នកវិនិយោគក៏នៅតែកើនឡើងនៅក្រុងព្រះសីហនុផ្ទាល់។ មួយវិញទៀតរាល់កន្លែងកម្សាន្តនីមួយៗស្ថិតក្នុងចម្ងាយខុសគ្នា ដែលធ្វើឱ្យទីក្រុងក្លាយ ជាគោលដៅទេសចរណ៍បែបប្រណិត និង ជាកន្លែងសម្រាប់អ្នកដែលស្វែងរកភាពស្ងប់ស្ងាត់។

**២.១.២.៣. ផាសុកភាព**

ផាសុកភាព សំដៅទៅលើសេចក្តីសុខ សេចក្តីសម្រាន្ត សេចក្តីសប្បាយ។[27] ប៉ុន្តែប្រសិនបើន័យទូទៅយើងអាចឱ្យនិយមន័យ ផាសុកភាពបានថា ភាពស្រស់ស្រាយ ភាពសប្បាយរីករាយ មិនសៅម៉ង មិនធុញថប់ រស់នៅប្រកបដោយសុខដុមរមនា។ ដើម្បីទទួលបានផាសុកភាពមួយដែលជាទីគាប់ចិត្តរបស់យើងគ្រប់រូបដរាបណាមាន អនាម័យ និង បរិស្ថានល្អ។ តួយ៉ាងបញ្ហាពាក់ព័ន្ធនឹងការរៀបចំក្រុងមួយឱ្យទទួលបានផាសុកភាព ពិតជាមានសារៈសំខាន់ណាស់ ដើម្បីជាជំនួយក្នុងការផ្តល់ការរស់នៅមួយដែលល្អសម្រាប់ប្រជាជន តាមរយៈការផ្តល់សេវាសុខភាពសាធារណៈ និង ការគ្រប់គ្រងស្ថានភាពបរិស្ថានផងដែរ។

ជាការពិតណាស់ក្រុង ជាទីប្រជុំជនដែលមានការប្រមូលផ្តុំនូវចំនួនប្រជាជនច្រើនជាងនៅតាមជនបទ ជាពិសេសមានសកម្មភាពផ្សេងៗជាច្រើនដែលអាចនាំឱ្យក្រុងងាយទទួលរងផលប៉ះពាល់ពីការបំពុល បរិស្ថានកើតចេញពីរោងចក្រសិប្បកម្ម សហគ្រាស កាកសំណល់ផ្សេងៗ។

ដើម្បីឱ្យក្រុងមួយទទួលបានផាសុកភាពល្អប្រសើរ លុះត្រាតែមានការយកចិត្តទុកដាក់ខ្ពស់ និងផ្តោតសំខាន់ទៅលើបរិស្ថានស្អាត អនាម័យល្អដោយគ្មានកំហុសទាំង៥នេះ ដូចជាៈ

- **ការបំពុលទឹក ៖** ការបំពុលទឹក គឺជាការធ្វើឱ្យកង្វក់ទឹក នៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ដកយកសារធាតុបំពុលចេញ)។ ការបំពុលទឹកភាគច្រើន គឺបណ្តាលមកពីការគ្រប់គ្រងសំរាមមិនបានល្អ ការគ្រប់គ្រងប្រព័ន្ធទឹកកង្វក់មិនបានល្អ ដូចជាកាកសំណល់ដែលចេញពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះ ហើយគ្មានវិធានការចំពោះប្រជាពលរដ្ឋដែលមិនបានប្រើប្រាស់បង្គន់អនាម័យមិនបានត្រឹមត្រូវ ដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វ ក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។ មួយវិញទៀតការបំពុលទឹកធ្វើឱ្យប្រភពទឹកដូចជា សមុទ្រ ទន្លេ បឹងបួ ស្ទឹង ព្រែក កខ្វក់ គ្មានអនាម័យ ចំពោះបញ្ហានេះ

[27] សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ

ត្រូវបានគេយកចិត្តទុកដាក់ជាខ្លាំង ព្រោះវាទាក់ទងនឹងបញ្ហាសុខភាពគ្រប់ភាវៈមានជីវិតទាំងអស់។ ប្រសិនបើសត្វ និង រុក្ខជាតិដែលរស់នៅក្នុងទន្លេ ស្ទឹង បឹងបួ ឬ សមុទ្រ ដែលមានការបំពុលទឹកនោះជីវិតរបស់ពួកវានឹងត្រូវបានបំផ្លាញ ប្រសិនបើការដាំដំណាំ ដោយការប្រើប្រាស់ប្រភពទឹកនោះ វាអាចធ្វើឱ្យខូចខាតផលដំណាំ ឬ អាចប៉ះពាល់ដល់អាយុជីវិតសត្វ និង មនុស្ស នៅពេលដែលបរិភោគបន្លែ ដែលមានជាតិពុល។ ដូចនេះហើយទើបមានវិធានការទប់ស្កាត់កុំឱ្យមានការបំពុលទឹកជាច្រើនដូចជាការបង្កើតអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹកក្នុងគោលបំណងទប់ស្កាត់ និង ការកាត់បន្ថយការបំពុលទឹក ដែលបានសំដៅទៅលើការធានាការការពារសុខភាពមនុស្ស និង អភិរក្សជីវៈចម្រុះ។[28] ជាការពិតណាស់ការបំពុលទឹកកើតឡើងដោយកត្តាចម្បងពីរសំខាន់ៗដូចជា៖

- **កត្តាមនុស្ស ៖** រាល់សកម្មភាពមនុស្ស គឺជាមូលហេតុ នៃការបង្កជាការបំពុលទឹក តាមរយៈការបង្ហូរទឹកកខ្វក់ដែលមានកាកសំណល់រឹង រាវហើយបញ្ចេញចោលទៅក្នុងប្រភពទឹក។ ចំពោះកាកសំណល់ទាំងអស់អាចផ្ទុក និង បញ្ចេញនូវសារធាតុគីមី ឬ ជាតិពុលផ្សេងៗ ដែលមិនអាចមើលដោយភ្នែកទទេឃើញឡើយ។ មួយវិញទៀតសំណល់រឹង ក៏ជាកត្តាមួយដែលធ្វើឱ្យមានការបំពុលដែរ ឬ ឯសំណល់រាវ គឺសំដៅទៅលើសារធាតុរាវដែលបញ្ចេញជាតិពុល។ ចំពោះកាកសំណល់ទាំងពីរប្រភេទនេះ ត្រូវបានបញ្ចេញពីប្រភពបំពុល ដែលមានដូចជាទីតាំងអគារទាំងឡាយ រួមមានលំនៅដ្ឋាន និង អគាររដ្ឋបាលសាធារណៈ ទីបរិវេណមធ្យោបាយដឹកជញ្ជូន និង តំបន់អាជីវកម្ម ឬ សេវាកម្មដែលបញ្ចេញនូវសំណល់រឹង រាវ សារធាតុបំពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ ទាំងប្រយោល និង ផ្ទាល់ទៅក្នុងតំបន់ទឹក មានដូចជា ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក ស្រះ អណ្តូង ឬចូលទៅក្នុងបណ្តាញលូសាធារណៈផងដែរ។
- **កត្តាធម្មជាតិ ៖** បាតុភូតធម្មជាតិគឺ កើតឡើងដោយឯកឯង យើងមិនអាចទប់ស្កាត់បាន គ្មានការព្រាងទុកមុននោះទេ ហើយបញ្ហាគ្រោះធម្មជាតិក៏បាន បង្កឱ្យមានការបំពុលទឹកដូចជាគ្នាផងដែរ។ ជាក់ស្តែងគ្រោះធម្មជាតិដែលបានកើតឡើងមានដូចជា គ្រោះទឹកជំនន់ដែលអាចនាំសារធាតុពុលមួយចំនួនហូរចូលទៅក្នុងទឹកបាន, បន្ទុះភ្នំភ្លើងដែលបញ្ចេញនូវកម្អែភ្នំភ្លើងដែលមានកម្តៅក្តៅខ្លាំង និង អាចធ្លាក់ចូលទៅក្នុងទឹក ដែលអាចបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ភាវៈរស់ និង រុក្ខជាតិដែលរស់នៅក្នុងទឹក។ ជាពិសេសទៅទៀតនោះភ្លៀងអាស៊ីតក៏ជាបញ្ហាចម្បងដែលបង្កឱ្យមានការបំពុលទឹកផងដែរ ដោយវាបានធ្លាក់ពីលើអាកាសនាំយកឧស្ម័នពុល មកកាន់ផែនដី បឹងបួ សមុទ្រ ទន្លេ បណ្តាលឱ្យមានការបំពុលទឹក និង

[28] អនុក្រឹត្យលេខ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក, មាត្រា១

រុក្ខជាតិ ឬ ដើមឈើមួយចំនួនទទួលរងគ្រោះដល់អាយុជីវិត ក៏ព្រោះតែទឹកភ្លៀងនេះនាំចូលឧស្ម័នដែលមានជាតិពុលហើយវាក៏មានឥទ្ធិពលដល់ដី ដំណាំផ្សេងៗថែមទៀតផង។

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង ក្រសួងដែនដីនគរូបនីយកម្ម បានសហការជាមួយក្រសួងជំនាញដទៃ គ្រោងពង្រីកអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅ ក្រុងព្រះសីហនុឱ្យកាន់តែប្រសើរ ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និង ការអភិវឌ្ឍ ក៏ដូចជាទប់ស្កាត់ការបង្ហូរទឹកកង្វក់ចូលទៅក្នុងសមុទ្រ ដែលធ្វើឱ្យខូចបរិស្ថាន និង ប៉ះពាល់ទឹកសមុទ្រ។

➢ **ការបំពុលដី ៖** ដោយយើងបានដឹងថា ដីមានសារៈសំខាន់ខ្លាំងណាស់ក្នុងការផ្តល់ជីជាតិ ជួយសម្រួលដល់ការដាំដុះផ្សេងៗ ហើយគ្រប់ដំណាំនឹងត្រូវខូចខាត អាចប៉ះពាល់ដល់ការបរិភោគរបស់មនុស្ស និង សត្វថែមទៀតផង។ ជាការពិតណាស់ការបំពុលដី មានន័យថាដីត្រូវបានបំពុលដោយគីមីជ្រាបចូល ឬ មានសារធាតុជាច្រើនទៀត ដែលបានបង្កឱ្យដីមានការខូចខាត ដោយសារការបំពុលសារធាតុគីមី ការចោលសំណល់រឹង រាវគ្រប់ប្រភេទ ឬ ធ្លាយប្រេងពីគ្រឿងរថយន្ត សំណល់សម្ភារៈសំណង់។ ដូច្នេះហើយមានកត្តាមួយចំនួនដែលបណ្តាលឱ្យមានការបំពុលដីដូចជា៖

- **ការបំពុលដោយសកម្មភាពមនុស្ស ៖** សកម្មភាពរបស់មនុស្សប្រចាំថ្ងៃជា បញ្ហាចម្បងមួយដែលអាចនាំឱ្យមានការបំពុលដីយ៉ាងច្រើន ដោយការបំពុលដី គឺបណ្តាលមកពីការប្រើប្រាស់ និង ការបន្សល់ទុកនូវសំរាមដែលផ្ទុកនូវសារធាតុពុលនៅក្នុងនោះជាច្រើន ហើយមិនបានធ្វើការគ្រប់គ្រងសំរាមទាំងនោះឱ្យបានល្អ និង ត្រឹមត្រូវ ទើបធ្វើឱ្យមនុស្សនៅតំបន់មួយចំនួនធ្វើការបោះចោលសំរាមពាសវាលពាសកាលទៅលើដី ឬម្យ៉ាងទៀតអាចយកសំរាមទៅកប់ចោលនៅក្នុងដីទាំងដែលសំណល់ខ្លះមិនរលាយ ដែលជាហេតុធ្វើឱ្យកាកសំណល់ទាំងអស់នោះជ្រាបចូលទៅក្នុងដី ចាប់ផ្តើមខូចគុណភាពដីម្តងបន្តិចៗ។
- **ការបំពុលដោយកសិកម្ម ៖** ដើម្បីឱ្យ ការដាំដំណាំ ធ្វើស្រែចម្ការ បន្លែផ្លែឈើ ទទួលបានផលឆាប់រហ័សល្អជាទីគាប់ចិត្ត កសិករត្រូវការប្រើប្រាស់ថ្នាំបាញ់សម្លាប់សត្វល្អិត ក៏ដូចជាសត្វដង្កូវផងដែរ។ ការដែលយកជី មិនបានត្រឹមត្រូវ ឬថ្នាំសម្លាប់សត្វចង្រៃជាកត្តាធ្វើឱ្យមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ។
- **ការបំពុលដោយកាកសំណល់ឧស្សាហកម្ម ៖** រោងចក្រឧស្សាហកម្មជាកន្លែងមួយដែលប្រមូលផ្តុំនូវវត្ថុធាតុជាច្រើនដែលផ្ទុកនូវសារធាតុច្រើនមុខ ហើយនៅពេលដែលវត្ថុធាតុទាំងអស់នោះត្រូវយកទៅបំប្លែងកាកសំណល់ឧស្សាហកម្មដែលសល់ប្រាកដជាបញ្ចេញចោលទៅលើដី ដែលអាចធ្វើឱ្យមានជាតិពុល។ ជាក់ស្តែងដើម្បីឱ្យបរិស្ថានក្រុងព្រះសីហនុស្អាត និង ទប់ស្កាត់ការបំពុលដី ប្រជាជនតាមបណ្តាលខេត្តក្រុង គួរតែដាក់សំរាមឱ្យមានរបៀបរៀបរយ ដើម្បីឱ្យក្រុមហ៊ុនប្រមូលសំរាមងាយស្រួលក្នុងការប្រមូល។

មួយវិញប្រសិនបើសំរាមណាដែលអាចកែច្នៃឡើងវិញបាន គឺ លើកទឹកចិត្តឱ្យមានការកែច្នៃឡើងវិញ និង បញ្ឈប់រាល់ការដាក់សំរាម ឬ ចាក់ចោលសំណល់ទៅលើដី។

➢ **ការបំពុលខ្យល់ ៖** ខ្យល់បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការឱ្យមនុស្សគ្រប់រូបរស់នៅបានតាមរយៈខ្យល់ដកដង្ហើម ដោយមានការផ្លាស់ប្តូរខ្យល់ក្នុងខ្លួន និង ក្រៅខ្លួន។ មួយវិញទៀតការបំពុលខ្យល់មានប្រភពចេញពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាស៊ូត និង ធ្យូងសម្រាប់ការដឹកជញ្ជូន ការប្រើប្រាស់តាមផ្ទះ និង ការប្រើប្រាស់ក្នុង វិស័យឧស្សាហកម្ម និង ថាមពល។ ការដុតឥន្ធនៈទាំងនេះបានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាសដែលបង្កឱ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និង សុខភាពរបស់មនុស្ស ជាក់ស្តែងរាល់សកម្មភាពរបស់មនុស្សជាកត្តាចម្បងមួយ ដែលបានបង្កឱ្យមានការបំពុលគ្រប់រូបភាព ហើយសកម្មភាពមួយចំនួនដែលបង្កជាការបំពុលខ្យល់មានដូចតទៅ៖

- ***សកម្មភាពឧស្សាហកម្ម*** ៖ តំបន់ឧស្សាហកម្មសម្បូរទៅដោយរោងចក្រឧស្សាហកម្ម ដែលពោរពេញទៅដោយកន្លែងដែលបញ្ចេញថាមពលច្រើន ហើយមានផ្ទុកសារធាតុគីមី និង មានការបំពុលដោយសារការសាយភាពចេញនូវផ្សែងឬ ឧស្ម័នពុលនិងសារធាតុគ្រោះថ្នាក់ផ្សេងៗទៀតដែលបន្សល់ពីកាកសំណល់ឧស្សាហកម្មទៅខ្យល់អាកាស។
- **ការបោះចោល និង ទុកដាក់សំរាម** ៖ ចំពោះសំរាម និង កាកសំណល់ដែលបានបន្សល់ពីការប្រើប្រាស់រួចរាល់ហើយការវេចខ្ចប់ និង ការទុកដាក់បានមិនត្រឹមត្រូវ វាអាចជះឥទ្ធិពលតិចតួចដល់បរិស្ថាន និង បរិយាកាសជុំវិញ។ ម្យ៉ាងវិញទៀត ប្រសិនបើកាកសំណល់នោះត្រូវបានយកទៅដុត ឬ កម្ទេចចោលអាចមានភាគរយច្រើនដែលធ្វើឱ្យបរិយាកាសមានសភាពអាប់អួរ ក្លិនមិនល្អ និង បណ្តាលឱ្យមានការបំពុលខ្យល់អាកាសហើយអាចឈានទៅដល់ការកើនឡើងកម្តៅផែនដីផងដែរ។

ដើម្បីទប់ស្កាត់ និង កាត់បន្ថយការបំពុលខ្យល់ឱ្យស្របតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំឡេង ម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលខុសត្រូវប្រភពបំពុលត្រូវ៖

- ទទួលខុសត្រូវក្នុងការដំឡើង ឬពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និង ឧបករណ៍សម្រាប់កាត់បន្ថយសំឡេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្តង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និង ត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ ខែ ម្តង។

- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូបជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និង រៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាល តាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ។[29]

➢ **ការរំខានដោយសំឡេង ៖** ការរំខានដោយសំឡេង គឺជាការបំពុលមួយដែលមានផលប៉ះពាល់យ៉ាងខ្លាំង ទៅដល់ការរស់នៅរបស់មនុស្ស ធ្វើឱ្យមនុស្សចាប់ផ្តើមធុញថប់នៅក្នុងអារម្មណ៍។ ជាក់ស្តែងសកម្មភាពរបស់ ប្រជាជនសព្វថ្ងៃមានច្រើនរូបភាព ដែលបង្កឱ្យមានការរំខានកើតឡើង ដូចជា ការបញ្ឆេះយានយន្ត ការកែច្នៃ យានជំនិះ យានយន្ត មិនបានត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស។ ម្យ៉ាងវិញទៀតការរំខានដោយសំឡេងបែងចែក ជាពីរប្រភព គឺប្រភពចល័ត សំដៅទៅលើប្រភពដែលមិនស្ថិតនៅទីកន្លែងណាមួយជាក់លាក់ ដូចជា យានយន្ត គ្រឿងយន្ត យន្តហោះ នាវាដឹកជញ្ជូន និង គ្រឿងសំឡេងគ្រប់ប្រភេទ។ ប្រភពមួយទៀតនោះ គឺជាប្រភពអចល័ត ដែល ប្រភពនេះស្ថិតនៅទីតាំងជាក់លាក់ណាមួយ ក្នុងនោះមានដូចជា រោងចក្រ ការដ្ឋានសាងសង់ សហគ្រាស សិប្បកម្ម និង សកម្មភាពផ្សេងទៀតដែលដំណើរការនៅទីកន្លែងអចិន្ត្រៃយ៍មួយ។[30]

- **ការបំពុលតាមរយៈប្រភពចល័ត** ៖ ប្រភពចល័តដែលមានសំឡេងមិនស្ថិតនៅមួយកន្លែងក៏ជាកត្តា ដែលបង្កការរំខានដល់អ្នកដទៃផងដែរ ដូចជា រថភ្លើង, យន្តហោះ សំឡេងចេញពីឃោសនសព្ទ ឬ ម៉ាស៊ីនយានយន្តគ្រប់ប្រភេទ ហើយអ្វីដែលសំខាន់គឺប្រភេទយានយន្តដែលចាស់រហូតដល់ម៉ាស៊ីនបន្លឺ សំឡេង ម្យ៉ាងទៀតចំពោះរថយន្តកែច្នៃដែលអត់មានស្តង់ដារត្រឹមត្រូវ។
- **ការបំពុលតាមរយៈប្រភពអចល័ត** ៖ ចំពោះការបំពុលសំឡេងពីប្រភពអចល័តអាចជាការរំខានយ៉ាង ខ្លាំងដែរ ពីព្រោះការដែលមិនផ្លាស់ទី ឬ នៅមួយកន្លែងក្នុងរយៈពេលណាមួយ។ ដោយឧទាហរណ៍ថា រោងចក្រមួយចំនួនមិនត្រូវបានការអនុញ្ញាតសាងសង់នៅក្នុងទីប្រជុំជនពិតមែន តែក៏មិនមែនមានន័យ ថា គ្មានផ្ទះប្រជាជននៅក្បែររោងចក្រនោះទេ ពីព្រោះកាលដែលមានរោងចក្រនៅជិតផ្ទះវាក៏អាចធ្វើឱ្យ មានការរំខានដល់ការរស់នៅ ដោយសារតែមានសំឡេងម៉ាស៊ីនដែលដំណើរការក្នុងរោងចក្រមាន សំឡេងចេញខាងក្រៅ។

ក្រសួងមហាផ្ទៃ បានចេញ សេចក្តីណែនាំស្តីពីការលុបបំបាត់ការបង្កសំឡេងរំខានលើសកម្រិត ដោយ យានយន្តគ្រប់ប្រភេទ ដែលណែនាំឱ្យអាជ្ញាធរលុបបំបាត់ចំពោះការកែច្នៃបំពង់ស៊ីម៉ាំង ដែលបង្កភាពរំខានដល់ អារម្មណ៍ប្រជាពលរដ្ឋ។ មួយវិញទៀតដើម្បីកាត់បន្ថយការរំខានដោយសំឡេងមានដូចជា៖

[29] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុល និងការរំខានដោយសំលេង, មាត្រា២៤

[30] អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង, មាត្រា៣

- ឧបករណ៍កាត់បន្ថយសំឡេង ត្រូវបំពាក់នៅពេលដែលយល់ថា មានការចាំបាច់ ដើម្បីកាត់បន្ថយសំឡេងពីម៉ាស៊ីន និង គ្រឿងចក្រផ្សេងៗ។
- ក្រុមហ៊ុន នឹងប្រើប្រាស់ម៉ាស៊ីន និង គ្រឿងចក្រទំនើប ដែលបញ្ចេញសំឡេងតិច និង កាត់បន្ថយរំញ័រ ដែលមិនធ្វើឱ្យមានការរំខានដល់កម្មករ និង ជីវៈចម្រុះក្នុងសមុទ្រ។
- ចំពោះបុគ្គលិក និង កម្មករដែលប្រឈមទៅនឹងសំឡេងខ្លាំង និង មានរយៈពេលយូរ នោះត្រូវបំពាក់ប្រដាប់ការពារត្រចៀកដល់បុគ្គលិក-កម្មករ។

➢ **ការបំពុលដោយសំណល់រឹងរាវ ៖** ការបំពុលនេះក៏ធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់មនុស្សយ៉ាងធ្ងន់ធ្ងរដោយសារតែជាកាកសំណល់ដែរមានជាតិពុល អាចឱ្យមានការបំពុលដី និង បរិយាកាសបាន។ មួយវិញទៀតការបំពុលនេះបណ្តាលមកពីការបោះចោលសំរាម ឬ ការបង្ហូរទឹកកខ្វក់ចូលស្ទឹង បឹងបួជាដើម ប្រសិនបើមនុស្សមិនបានគ្រប់គ្រងរបបអាហាររបស់ខ្លួនឱ្យបានត្រឹមត្រូវនោះទេ អាចមានរុយដែលមានមុខងារចម្លងមេរោគដែលហើរមកទំលើសំរាមទាំងនោះ។ ជាការពិតណាស់នៅតាមលំនៅដ្ឋាននីមួយៗបានបង្កបង្កើនសំរាមជារៀងរាល់ថ្ងៃដោយសំរាមខ្លះគេអាចយកទៅកែច្នៃឱ្យទៅជារបស់មានប្រយោជន៍បាន ដូចជា សំណល់ដែលចេញពីផ្ទះបាយជាដើម រីឯសំណល់ខ្លះទៀតអាចមានជាតិពុលដែលប៉ះពាល់ដល់ភាវៈមានជីវិតផងដែរ មិនថានៅក្រោមដី ឬនៅលើដី។

- **សំណល់រឹង** ៖ គឺជាសំរាម ឬ របស់របរទាំងឡាយណាដែលមានរូបភាពរឹង ហើយពុំត្រូវការ ឬ មិនអាចប្រើប្រាស់តទៅទៀតបាន ហើយត្រូវបានគេបោះបង់ចោលទៅក្នុងបរិស្ថានដែលយើងរស់នៅសព្វថ្ងៃ។ ចំពោះសំណល់រឹងមានដូចជា ថង់ប្លាស្ទិច ក្រដាស ក្រណាត់លោហៈ បន្លែ ផ្លែឈើ សំបកដប សំបកកំប៉ុង និងសំណល់ដែលចេញពីសំណល់វិទ្យុសកម្មផ្សេងៗទៀត។
- **សំណល់រាវ** ៖ សំដៅទៅលើលូ(ទឹកកខ្វក់) ឬវត្ថុរាវដែលបានបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬ ចូលទៅក្នុងបណ្តាញលូសាធារណៈដូចជា ការសាងសង់បង្គន់តាមគេហដ្ឋាន អាហារដ្ឋាន សណ្ឋាគារមួយចំនួនខុសបច្ចេទេស ដោយបង្ហូរផ្ទាល់ចូលទៅក្នុងប្រព័ន្ធលូសាធារណៈ ហើយថែមទាំងការមិនចូលរួមថែរក្សាប្រព័ន្ធលូជាដើម។

រដ្ឋបាលខេត្តព្រះសីហនុ មន្ទីរបរិស្ថានខេត្តព្រះសីហនុ បាននឹងកំពុងធ្វើការសម្អាតអនាម័យបរិស្ថាន និងការគ្រប់គ្រងសំណល់រឹងរាវ និង ស្តារប្រឡាយផ្សេងៗដើម្បីរំដោះទឹកឱ្យបានឆាប់រហ័ស។ ជាមួយគ្នានេះដែរ នៅក្នុងក្រុង និង នៅតាមតំបន់ឆ្នេរ អ្នកសម្អាតអនាម័យបរិស្ថានបានបោសសម្អាត រេចខ្ចប់ទុកដាក់សំរាមឱ្យបានត្រឹមត្រូវដើម្បីរក្សាសោភ័ណភាពទីក្រុង និង ឆ្នេរសមុទ្រកម្ពុជាឱ្យស្រស់ស្អាត។

**២.១.២.៤. កាត់បន្ថយការកកស្ទះចរាចរណ៍នាថ្ងៃឈប់សម្រាក**

ដោយយោងទៅតាមប្រសាសន៍របស់**លោក សន កុសល** អភិបាលរង ក្រុងព្រះសីហនុ ការចុះរៀបចំសណ្តាប់ធ្នាប់នៅក្នុងទីក្រុងដូចជា ការរៀបចំទុកដាក់សម្ភារសំណង់លើចំណីផ្លូវ ការចតរថយន្តលើចិញ្ចើមផ្លូវ ជាដើម ក្នុងគោលបំណងដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ នៅថ្ងៃឈប់សម្រាក តួយ៉ាងបុណ្យជាតិ ដែលមានភ្ញៀវជាតិនិង អន្តរជាតិ មកលេងកម្សាន្តអាចបង្កឱ្យមានការកកស្ទះចរាចរណ៍។ លោកក៏បានបញ្ជាក់ទៀតថាការការចុះរៀបចំសណ្តាប់ធ្នាប់នេះ គឺលោកបានធ្វើទូទាំងក្រុងតែម្តង ដោយចំណាត់ការនេះ មានប្រជាពលរដ្ឋស្ទើរតែគ្រប់គ្នាបានគាំទ្រ និង លើកទឹកចិត្តដែលតម្រូវឱ្យមានការអនុវត្តបន្តទៅមុខទៀតដើម្បីឱ្យសោភ័ណភាពទីក្រុងព្រះសីហនុក្លាយជា ទីក្រុងមួយដែលមានទេសចរណ៍ដ៏ស្រស់ស្អាតនាទិសនិរតីនៅពេលអនាគតដ៏យូរអង្វែង។[31] ដូចនេះដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ថ្ងៃឈប់សម្រាកមានដូចជា ៖

- **កាត់បន្ថយការប្រើប្រាស់យានយន្ត និង ការរំលោភបំពានលើចំណីផ្លូវ** ៖ អាជ្ញាធរត្រូវមានយន្តការកំណត់ចំនួនយានយន្តប្រើប្រាស់ ការនាំចូល និង ចាត់វិធានការណ៍ច្បាស់លាស់ចំពោះអ្នករកស៊ីណាដែលបានរំលោភបំពានលើចំណីផ្លូវនៅពេលមានបុណ្យទាន។ ផ្ទុយទៅវិញពលរដ្ឋគួរតែងាកមកប្រើប្រាស់សេវាសាធារណៈរបស់សាលាក្រុងនិងកាត់បន្ថយការប្រើប្រាស់រថយន្តតែម្នាក់ឯង។
- **អ្នកប្រើប្រាស់ដងផ្លូវត្រូវប្តូរឥរិយាបថក្នុងការបើកបរ** ៖ អ្នកបើកបរត្រូវគោរពតំនូសសញ្ញាចរាចរណ៍ បើកតាមគន្លងដែលបានចែក និង មិនបំពានផ្លូវអាទិភាពរបស់អ្នកដទៃ។ ដើម្បីឱ្យចរាចរណ៍ក្នុងក្រុងមានភាពល្អប្រសើរ ពេលថ្ងៃឈប់សម្រាក ទាំងបណ្តាអ្នកប្រើប្រាស់ផ្លូវថ្នល់គ្រប់រូប គួរគិតមើលសារជាថ្មីអំពីការប្រើប្រាស់ទ្រូងផ្លូវ និង របៀបប្រើប្រាស់ទ្រូងផ្លូវឱ្យមានប្រសិទ្ធភាព។

## ២.២. ផលវិបាកនៃការរៀបចំ

គ្រប់ដំណើរការរៀបចំក្រុងនីមួយៗ រមែងតែជួបប្រទះនូវផលលំបាក និង បញ្ហាជាច្រើន ដូចជាតម្រូវការខ្ពស់ទាំងសម្ភារៈ និង ប្រភពធនធានដទៃទៀត។ ចំពោះឧបករណ៍ជាក់ស្តែងដើម្បីសាងសង់ស្ពានមួយបានគេត្រូវការឧបករណ៍ និង សម្ភារៈសំណង់ជាច្រើន ព្រោះការធ្វើស្ពានមានទំហំធំ ជាពិសេសវាទាមទារនូវទំហំពលកម្មជាច្រើនក៏ដូចជាប្រាក់ឈ្នួលសម្រាប់កម្មករផងដែរ។ លើសពីនេះដើម្បីឱ្យសំណង់ស្ពានអាចទ្រទ្រង់បានល្អ ដរាបណាការគណនាបានច្បាស់លាស់ ម៉ត់ចត់ និង ការសាងសង់ត្រូវតាមស្តង់ដារមាត្រដ្ឋានត្រឹមត្រូវ។

---

[31] អាជ្ញាធរក្រុងព្រះសីហនុ ចុះរៀបចំសណ្តាប់ធ្នាប់ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងឱកាសថ្ងៃឈប់សម្រាក | សារព័ត៌មាននគរវត្ត (nokorwatnews.com) (ចូលទស្សនាចុងក្រោយ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១)

### ២.២.១. ធនធានមនុស្ស

ធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ដែលមិនអាចខ្វះបាននៅក្នុងការរៀបចំទីក្រុង ទោះបីស្ថិតក្នុងសម័យកាលណាក៏ដោយ។ សកលភាវូបនីយកម្មបាននាំយកសម្ភារៈទំនើបដោយការប្រើប្រាស់គ្រឿងយន្តមកជំនួសកម្លាំងមនុស្សក៏ពិតមែន ប៉ុន្តែនៅតែត្រូវការគ្រប់គ្រងពីមនុស្សដូចគ្នា។ យ៉ាងណាមិញ ដោយយោងទៅតាមប្រសាសន៍របស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**កាលពីថ្ងៃទី ២៥ ខែមិនា ឆ្នាំ២០១៩ បានឱ្យឃើញថា ធនធានមនុស្សសំខាន់ៗជាច្រើននៅកម្ពុជាពុំទាន់មានគ្រប់គ្រាន់នៅឡើយទេ ដោយហេតុថា ធនធានមនុស្សក្នុងវិស័យសំខាន់ៗ ដូចជា វិស្វកម្មសំណង់ និង បច្ចេកវិទ្យា នៅមានកម្រិតនៅឡើយ។[32] ធនធានមនុស្សនៅក្រុងព្រះសីហនុបានកត់សម្គាល់ឃើញថាមានការកើនឡើងជាលំដាប់ ដោយសារតែលំហូររបស់ជនជាតិដទៃប៉ុណ្ណោះ តួយ៉ាងជនជាតិចិនដែលមានប្រមាណជាង ១ ពាន់នាក់ ដោយយោងតាមកំណត់ត្រារបស់គេហទំព័រអាស៊ីសេរី ២០២០ គិតចាប់តាំងពីចុងខែ ឧសភា ដល់ ដើមខែមិថុនា។ ដោយឡែកធនធានមនុស្សនៅក្នុងទីក្រុងព្រះសីហនុផ្ទាល់មានការថយចុះ ដោយសារតែបញ្ហាសេដ្ឋកិច្ច ដូច្នេះធ្វើឱ្យមានការធ្វើចំណាកស្រុកទៅទីក្រុង ឬ ប្រទេសជិតខាង។

### ២.២.២. គម្រោងថវិកា

ប្រទេសកម្ពុជាស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ និង នៅតំបន់ខ្លះទៀតមិនទាន់រីកចម្រើនដូចប្រទេសអភិវឌ្ឍន៍មួយចំនួននោះទេ ដោយហេតុថាប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមជាច្រើន ជាពិសេសសង្គ្រាមផ្ទៃក្នុងដែលអូសបន្លាយអស់រយៈពេល៣ ឆ្នាំ ៨ខែ ២០ថ្ងៃ។ ក្រោយថ្ងៃរំដោះរាជរដ្ឋាភិបាលបានព្យាយាមអភិវឌ្ឍន៍រហូតបានដល់ពេលបច្ចុប្បន្ន។ ងាកមកមើលគម្រោងអភិវឌ្ឍន៍នីមួយៗវិញ គឺត្រូវការចំណាយដើមទុនច្រើន ហើយជាញឹកញាប់ប្រទេសកម្ពុជាតែងតែទទួលបានជំនួយមានសំណង និងឥតសំណងជាច្រើនពីបណ្តាប្រទេសផ្សេងៗ។

ជាទូទៅដើម្បីដំណើរការរៀបចំក្រុងបាន លុះត្រាតែមានការដាក់សំណើទៅថ្នាក់ជាតិ ដោយរង់ចាំការអនុញ្ញាត និង កញ្ចប់ថវិកាជាតិដែលផ្តល់សម្រាប់ការអភិវឌ្ឍ។ ដូច្នេះប្រសិនបើខាងថ្នាក់ជាតិអនុញ្ញាត និងភ្ជាប់មកជាមួយនូវកញ្ចប់ថវិកា វាមិនជាបញ្ហានេះទេ។ គួរបញ្ជាក់ផងដែរថា គម្រោងផ្លូវ ១១ ខ្សែនេះ ជាគម្រោងបន្ថែមពីលើគម្រោងផ្លូវ ៣៤ ខ្សែ ដែលទើបតែស្ថាបនារួចកាលពីថ្មីៗនេះ ដោយប្រើថវិកាជិត ៣០០ លានដុល្លារ។ លើសពីនេះទៅទៀត ផ្លូវដែលកំពុងសាងសង់នេះ ជាសមិទ្ធផលដែលកើតឡើងនៅក្នុងស្រុកចំនួន ២ គឺស្រុកព្រៃនប់ និង ស្រុកស្ទឹងហាវ។ គួរបញ្ជាក់ផងដែរថា គម្រោងផ្លូវ ១១ ខ្សែនេះ ជាគម្រោងបន្ថែមពីលើគម្រោងផ្លូវ ៣៤ ខ្សែ

[32] https://www.construction-property.com/km/pm-cambodias-construction-human-resources-must-strengthen-their-capacity/ (ចូលទស្សនាចុងក្រោយថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២១)

ដែលទើបតែស្ថាបនារួចកាលពីថ្មីៗនេះ ដោយប្រើថវិកាជិត ៣០០ លានដុល្លារ។ ក្រៅពីគម្រោងទាំង២ នេះ ខេត្តព្រះសីហនុក៏កំពុងមានគម្រោងធំជាច្រើនទៀត ដូចជាផ្លូវល្បឿនលឿន កំពង់ផែ ព្រលានយន្តហោះអន្តរជាតិ អាងប្រព្រឹត្តកម្មទឹកកខ្វក់ និង ទីលានចាក់សំរាមជាដើម ដែលនឹងបង្ហាញខ្លួនជាបន្តបន្ទាប់។[33]

ទាំងអស់នេះបានបញ្ជាក់ឱ្យឃើញថា សម្រាប់គម្រោងថវិកាជាតិក្នុងការដំណើរការគម្រោងនីមួយៗតែមួយចំណែកគឺមិនគ្រប់គ្រាន់នោះទេ ដរាបណាមានជំនួយ និង កម្ចីពីស្ថាប័នដទៃទៀត។ ជាការពិតណាស់រាល់ការកម្ចីទាំងអស់សុទ្ធតែមានសំណងសងទៅម្ចាស់បំណុល ទោះបីក្រោមទម្រង់រូបភាពបែបណាក៏ដោយដូចជាការសងត្រឡប់ជាសាច់ប្រាក់ ឬ ជាផលប្រយោជន៍ផ្សេងៗ។ ដូច្នេះរដ្ឋបាលទទួលបាននូវបន្ទុកចំពោះបញ្ហាថវិកាយ៉ាងធំធេង ក្នុងការបែងចែក គ្រប់គ្រងឱ្យមានស្ថេរភាពសេដ្ឋកិច្ច។

### ២.២.៣. កង្វះបច្ចេកទេស

ប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូច្នេះកង្វះបច្ចេកទេសក៏ជាកត្តាដ៏ចម្បងក្នុងការរារាំងការរៀបចំទីក្រុង ដោយមូលហេតុកង្វះបច្ចេកទេស មិនទាន់មានឧបករណ៍ទំនើបក្នុងការសាងសង់ ក៏ដូចជារៀបចំសោភ័ណភាពជាដើម។ អ្វីដែលគួរឱ្យកត់សម្គាល់មិនត្រឹមតែកង្វះនូវឧបករណ៍ប៉ុណ្ណោះទេ តែខណៈដែលប្រទេសកម្ពុជាទើបតែងើបពីសង្គ្រាមប៉ុន្មានសតវត្សន៍ចុងក្រោយទើបធ្វើឱ្យបាត់បង់នូវបុគ្គលឆ្នើម ក៏ដូចជាអ្នកមានចំណេះដឹងជាច្រើន។ ជាហេតុបណ្តាលឱ្យទាមទារនូវបុគ្គល ដែលមានជំនាញខ្ពស់ជាច្រើនក្នុងការអភិវឌ្ឍ ដោយសារជំនាញបច្ចេកទេសក្នុងស្រុកនៅមានកម្រិតទើបណ្តាបលឱ្យមាននូវតម្រូវការអ្នកបច្ចេកទេសពីបរទេស។

ជាការពិត វិស័យសំណង់ក្នុងពេលបច្ចុប្បន្នមិនត្រឹមតែរីកចម្រើននោះទេ គឺគម្រោងសាងសង់នីមួយៗកាន់តែប្រណិត និង ទំនើប ដូច្នេះវិស្វករដែលទើបតែចាប់ផ្តើមការងារ មិនអាចកាន់កាប់ការងារ សំខាន់ៗនោះទេលុះត្រាតែជាវិស្វករអាជីព ដែលមានបទពិសោធន៍ការងារច្រើនឆ្នាំ ទើបអាចទទួលឱកាសក្នុងការកាន់គ្រោងការនោះ។ នេះគឺជាបញ្ហាចោទដែលទាមទារឱ្យមានវិស្វករពីបរទេសដែលគេមានជំនាញ និង ការយល់ដឹងខ្ពស់ជាងវិស្វករ ដែលទើបប្រឡូកក្នុងការងារដែលមិនមែនជាវិស្វករអាជីពនោះទេ។

### ២.២.៤. ការបង្កអោយមានការកកស្ទះចរាចរណ៍

ជាក់ស្តែងនៅពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ ឬ មានការរៀបចំក្រុងរមែងតែមានការជួបប្រទះបញ្ហាការកកស្ទះចរាចរណ៍ ពីព្រោះការធ្វើផ្លូវថ្នល់ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយមានការបិទផ្លូវ ឬ បិទមួយជំហៀងផ្លូវដើម្បីឱ្យមានភាពងាយស្រួលក្នុងការកសាងស្ពាន ថ្នល់។ ដោយយោងទៅតាមមន្ត្រីនគរបាលចរាចរណ៍នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបំភ្លឺឱ្យសាធារណជនដឹងថា មូលហេតុដែលបង្កឱ្យមានការកកស្ទះខ្លាំង នៅតាមផ្លូវមួយចំនួន ជាពិសេសនៅពេលល្ងាច នៅទីប្រជុំជន ក្នុងក្រុងព្រះសីហនុរាល់ថ្ងៃនេះ ដោយសារ

[33] https://mpwt.gov.kh/kh/press/15942 (ចូលទស្សនាចុងក្រោយថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២១)

កត្តាមួយចំនួនមានដូចជា៖ កត្តាយានយន្តកើនច្រើន, ការបើកបរមិនគោរពច្បាប់ ឬ ការមិនគោរពភ្លើងសញ្ញា ។ លើសពីនេះទៅទៀត មានការបើកបរវ៉ាជែងគ្មានសណ្តាប់ធ្នាប់, បើកបរគ្មានសុជីវធម៌ មិនមានការប្រុងប្រយ័ត្ន បើកបរមិនប្រកាន់គន្លងផ្លូវ, ការបត់យានយន្ត ឆ្លងកាត់ផ្លូវមិនមើលស្ថានភាពចរាចរណ៍, ការបើកបរមិនមានការយោគយល់គ្នា និង ការចតយានយន្តនៅតាមចិញ្ចើមផ្លូវគ្មានសណ្តាប់ធ្នាប់ជាដើម គឺជាមូលហេតុចម្បងនាំឱ្យចរាចរណ៍កកស្ទះស្ទើររាល់ថ្ងៃ នៅទីប្រជុំជនក្នុងក្រុងព្រះសីហនុ។

ម្យ៉ាងវិញទៀតសាធារណជនបានផ្តល់យោបល់ថា ទាល់តែមានសមត្ថកិច្ចនគរបាលខេត្តព្រះសីហនុ ចាំបាច់ត្រូវតែពង្រាយកម្លាំង ប្រចាំការជួយសម្រួលចរាចរណ៍នៅតាមភ្លើងស្តុប និង តាមផ្លូវកោងនានាដែលមានចរាចរណ៍ឆ្លងកាត់ច្រើន ដើម្បីរង់ចាំជួយសំរួលចរាចរណ៍ជារៀងរាល់ថ្ងៃ ទើបអាចបញ្ចៀសការកកស្ទះចរាចរណ៍ក្នុងក្រុងព្រះសីហនុ មានភាពប្រសើរឡើង។

## ២.៣. ដំណោះស្រាយ

គ្រប់ដំណើរការនៃការរៀបចំក្រុងមួយ តែងតែមានការជួបប្រទះនូវបញ្ហាប្រឈមជាច្រើនក្នុងពេលអនុវត្តផែនការរយៈពេលវែង ដែលមានន័យថាគម្រោងនោះត្រូវការចំណាយដើមទុន និង ពេលវេលាយូរក្នុងការអនុវត្ត។ យ៉ាងណាមិញដើម្បីជាជំនួយដល់ការរៀបចំក្រុងនេះ គេអាចផ្តោតសំខាន់ទៅលើកត្តាពីរ មានដូចជា៖ **ការសហការពីប្រជាជន ។**

### ២.៣.១. ការសហការពីប្រជាពលរដ្ឋ

ជាក់ស្តែង រដ្ឋបាលក្រុងព្រះសីហនុបានខិតខំជួយសម្រួលដល់ការលំបាករបស់ប្រជាជនក្នុងការរស់នៅប្រចាំថ្ងៃ តាមរយៈការរៀបចំអភិវឌ្ឍខេត្ត ក្រុង ស្រុកទាំងអស់ ដោយធានានូវការអភិវឌ្ឍប្រកបដោយនិរន្តភាព។

ជាពិសេសទៅទៀតនោះ គ្រប់សកម្មភាពក្នុងការចូលរួមយោគយល់ អត់ឱន និងការអធ្យាស្រ័យពីសំណាក់ប្រជាពលរដ្ឋជាកត្តាសំខាន់មួយជំរុញដ៏ខ្លាំងក្លាក្នុងការអភិវឌ្ឍក្រុងឱ្យមានភាពជឿនលឿន។ ប្រជាជនគួរតែមានការសហការជាមួយនឹងអាជ្ញាធរមូលដ្ឋានក៏ដូចជា អាជ្ញាធរមានសមត្ថកិច្ចផងដែរក្នុងប្រការផ្សេងៗទាក់ទងនឹងកិច្ចការរៀបចំក្រុង។

**ឧទាហរណ៍**៖ ប្រសិនបើមានភាពពង្រីកទំហំផ្លូវដើម្បីសម្រួលចរាចរណ៍លើដងផ្លូវ ហើយច្បាស់ណាស់ថាការពង្រីកផ្លូវនេះ តែងតែប៉ះពាល់ដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋ នៅកន្លែងណាមួយជាក់ជាមិនខាន ដូច្នេះហើយអាជ្ញាធរត្រូវចុះសុំការសហការពីម្ចាស់ផ្ទះ ដោយមានការចរចាពីការខូចខាតផ្សេងៗក៏ដូចជា សំណងការខូចខាតផងដែរ។ ចំពោះករណីនេះ ក្នុងនាមជាម្ចាស់លំនៅឋានត្រូវមានការយោគយល់ដល់រដ្ឋ ដែលបានព្យាយាមផ្តល់ប្រយោជន៍រួមក្នុងសហគមន៍នោះ ដើម្បីឱ្យមានការសាងសង់ទៅដោយរលូន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយយោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្នុងទីក្រុង ពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍឱ្យមានភាពល្អប្រសើរ។ ការរៀបចំទីក្រុងឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ ជំរុញឱ្យមានការរីកចម្រើនទៅលើគ្រប់វិស័យ ដូចជាផ្នែកសេដ្ឋកិច្ច ទេសចរណ៍ ទូរគមនាគមន៍ ពាណិជ្ជកម្ម បរិស្ថាន ជាពិសេសទៅលើការគ្រប់គ្រងរដ្ឋបាល ដើម្បីឱ្យទទួលបានសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ មិនត្រឹមតែប៉ុណ្ណោះ ប្លង់គោល ដែលជាប្លង់តម្រង់ទិស ក្នុងការរៀបចំបែងចែកផ្ទៃដីតំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម កន្លែងចាក់សំរាម និង សួនសាធារណៈជាដើម ពិតជាមានសារៈសំខាន់ណាស់ដោយសារតែ ប្លង់គោលនេះ គឺ ជាផែនការដែលកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្ររួមក្នុងការអភិវឌ្ឍទីក្រុងនីមួយៗ។ តួយ៉ាងចំពោះក្រុងព្រះសីហនុ ដែលជាទីក្រុងកំពុងតែមានសន្ទុះសក្តានុពលយ៉ាងខ្លាំងក្លាទៅលើគ្រប់វិស័យ នាពេលបច្ចុប្បន្នមានការកែសម្រួលហេដ្ឋារចនាសម្ព័ន្ធ ពីគ្រប់មជ្ឈដ្ឋានអភិបាលក្រុងនិងអាជ្ញាធរពាក់ព័ន្ធគ្រប់បណ្តាថ្នាក់បានធ្វើការរៀបចំឱ្យទីក្រុងមានរបៀបរៀបរយឡើងវិញ នូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធដែលមានដូចជា ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធទឹកកខ្វក់ បណ្តាញលូ។ លើសពីនេះទៅទៀតអាជ្ញាធរមូលដ្ឋានក៏បានធ្វើការកែប្រែតំបន់មួយចំនួនឱ្យមាន ជាសុកភាព អនាម័យ ភាពស្ងប់ស្ងាត់ និង សុខសុវត្ថិភាព ក្នុងការរស់នៅរបស់ប្រជាជនផងដែរ។

យ៉ាងណាមិញការរៀបចំសណ្តាប់ធ្នាប់ និង សោភ័ណភាពតែងតែជួបប្រទះនូវបញ្ហាមួយចំនួនដូចជា កង្វះធនធានមនុស្ស កង្វះនូវជំនាញខាងផ្នែកបច្ចេកទេស ធ្វើឱ្យមានការកកស្ទះចរាចរណ៍ ដោយហេតុថាត្រូវធ្វើការបិទផ្លូវទាំងមូល ឬ មួយជំហៀង និងជាពិសេសទៅទៀតនោះមានបញ្ហាកង្វះថវិកាក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ប៉ុន្តែយ៉ាងណាក៏ដោយ បញ្ហាទាំងអស់នេះមិនអាចរាំងស្ទះក្នុងការរៀបចំទីក្រុងនោះទេ ដោយសារតែមានការសហការពីប្រជាជននៅក្នុងតំបន់នោះ។

សរុបមកទោះបីជាការរៀបចំទីក្រុងមានផលវិបាកនូវក្នុងការកែលម្អបន្តិចបន្តួចក៏ពិតមែន ប៉ុន្តែអាជ្ញាធរ និងសមត្ថកិច្ចដែលពាក់ព័ន្ធបានខិតខំរៀបចំឱ្យទីក្រុងទទួលបានសមិទ្ធផលជាទីគាប់ចិត្ត ដោយអាចជួយសម្រួលទៅដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលបានមកពីវិស័យផ្សេងៗ និង ផ្តល់ភាពងាយស្រួល ផ្តល់ទំនុកចិត្តសុខសុវត្ថិភាពនៅក្នុងការរស់នៅតាមតំបន់ភូមិ ឃុំ ជាដើម។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ក្នុងពេលបច្ចុប្បន្ននេះការអភិវឌ្ឍរបស់ក្រុងព្រះសីហនុមានការរីកចម្រើនយ៉ាងគួរឱ្យកត់សម្គាល់ ក៏ប៉ុន្តែការរៀបចំក្រុងឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់របស់ក្រុងព្រះសីហនុ នៅតែមានចំណុច និង ចន្លោះខ្វះខាតមួយចំនួន។ ដូច្នេះដើម្បីជាជំនួយដល់ការអភិវឌ្ឍ នាងខ្ញុំទាំងពីរសូមធ្វើការបញ្ចេញមតិយោបល់ និង សំណូមពរមួយចំនួនដូចខាងក្រោម៖

- ចូលរួមផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋនូវការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដើម្បីធានាឱ្យបាននូវសុខសុវត្ថិភាពក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ ដោយគណៈអភិបាលក្រុងមានការរឹតបន្តឹងកុំឱ្យមានអំពើណាមួយកើតឡើងដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ទីក្រុងដូចជា អំពើឆក់ប្លន់ ការជួញដូរគ្រឿងញៀន ការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និង អំពើជួញដូរមនុស្ស ពេស្យាចារជាដើម។
- ស្នើសុំឱ្យមានការរៀបចំទីកន្លែងចតយានយន្តឱ្យបានច្រើន និង ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវដែលពាក់ព័ន្ធទៅនឹងសោភ័ណភាពផ្លូវថ្នល់ ជាពិសេសត្រូវមានវិធានការតឹងរឹងទៅលើបុគ្គលណាដែលបានប្រើប្រាស់ចំណីផ្លូវធ្វើអាជីវកម្មផ្ទាល់ខ្លួនឬការចតរថយន្តដែលគ្មានរបៀបរៀបរយ គ្មានសណ្តាប់ធ្នាប់ដែលបង្កឱ្យមានបញ្ហាការកកស្ទះចរាចរណ៍។
- ស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធបំពាក់កាមេរ៉ាសុវត្ថិភាព ដើម្បីការពារសន្តិសុខ និង ចរាចរណ៍នៅក្នុងទីក្រុង។
- ស្នើសុំអាជ្ញាធរចុះផ្សព្វផ្សាយ អប់រំដល់ប្រជាពលរដ្ឋបន្ថែមពាក់ព័ន្ធទៅនឹងបញ្ហាសំរាម សំណល់រឹងរាវឱ្យបានញឹកញាប់ជៀសវាងកុំឱ្យមានការបំពុលទាំងប្រាំ មានដូចជា ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដោយសំណល់រឹងរាវ បំពុលដី បំពុលដោយសំឡេងជាដើម។ ជាពិសេសទៅទៀតនោះបន្ថែមការដាក់ឱ្យប្រើប្រាស់ធុងសំរាមទៅតាមប្រភេទសំរាមនីមួយៗរបស់សំរាម ដោយមានការដាក់ធុងសំរាមនៅតាមដងផ្លូវ សួនច្បារ រមណីយដ្ឋាន និងកន្លែងដើរកម្សាន្តសំខាន់ ដោយធ្វើការបង្ហាញដល់ប្រជាជនឱ្យចេះរក្សាអនាម័យខ្ពស់។ មួយវិញទៀតបង្កើតកន្លែងសម្រាប់អ្នកដែលចូលចិត្តពិសារបារីឱ្យនៅដាច់ឆ្ងាយពីគេជៀសវាងការបំពុលបរិស្ថាន។
- បង្កើតទូរគមនាគមន៍ ប្រព័ន្ធអ៊ិនធឺណិត ឱ្យបានច្រើនជាងមុននៅក្នុងក្រុងព្រះសីហនុ។
- ស្នើសុំឱ្យមានការដោះស្រាយនូវបញ្ហាដីឡើងថ្លៃខ្លាំង និង មានជម្លោះទន្ទ្រានយកដីគេមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយដីនោះមានទីតាំងស្ថិតនៅលើរមណីយដ្ឋានក្បាលឆាយ ដោយដីនៅទីនោះមានការកើនឡើងថ្លៃខ្លាំងដើម្បីលក់ឱ្យអ្នកវិនិយោគទុន។

# ឯកសារយោង

# ឯកសារយោង


**បទដ្ឋានគតិយុត្ត**

- អនុក្រឹត្យស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សាគណៈអភិបាលស្រុក
- អនុក្រឹត្យលេខ២៧ អនក្រ.បក ស្ដីពីការសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ នាំចូលដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា
- អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្ដីពីការត្រួតពិនិត្យការបំពុលទឹក
- អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្ដីពីការគ្រប់គ្រងសំណល់រឹងរាវ
- អនុក្រឹត្យលេខ ៤២ ស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- ប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រកាសលេខ ២៦៣ អ.តបង.ប្រក ស្ដីពីការកំណត់នីតិវិធីនៃការនាំចូលម្ហូបអាហារ

**សេចក្ដីសម្រេច/សេចក្ដីព្រាង/សេចក្ដីណែនាំ**

- សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង
- សេចក្ដីព្រាងអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

**សៀវភៅ**

- សៀវភៅនីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា(ឆ្នាំសិក្សា ២០១៩-២០២០)
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង សំរាប់គំរោងមរកត នៅក្រុងព្រះសីហនុ

**គេហទំព័រ**

- វិស័យ ទេសចរណ៍ ដើរតួ នាទី យ៉ាង សំខាន់ ក្នុង ការ រួមចំណែក កំណើន សេដ្ឋកិច្ចជាតិ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៥, ដកស្រង់ចេញពី https://kohsantepheapdaily.com.kh/article/129293.html (ចូលទស្សនាចុងក្រោយថ្ងៃទី១០ ឧសភា ២០២១)
- សៅ សុខអេង.២០២០. អាជ្ញាធរទុកដើមឈើចាំស្នេហ៍ឱ្យនៅកណ្ដាលផ្លូវទៅឆ្នេរអូរត្រេះ និងអូឈើទាលដើម្បីទាក់ទាញទេសចរ, ដកស្រង់ចេញពី https://thmeythmey.com/?page=detail&id=92448 (ចូលទស្សនាចុងក្រោយថ្ងៃទី៥ មិថុនា ២០២១)
- រមណីយដ្ឋានទឹកជ្រោះក្បាលឆាយ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦, ដកស្រង់ចេញពី http://vokc.org/article/167 (ចូលទស្សនាចុងក្រោយថ្ងៃទី៥ មិថុនា ២០២១)

- ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប, ដកស្រង់ចេញពី MONG RETHTHY GROUP (ចូលទស្សនាចុងក្រោយថ្ងៃទី ១៥ មិថុនា ២០២១)
- ក្រោយផ្លូវដែកដំណើរការឡើងវិញ តើវិស័យនេះវិវត្តដល់ណាហើយ?. ២០១៩, ដកស្រង់ចេញពី https://construction-property.com/km/the-kingdoms-railway-reopening-how-it-progresses/ (ចូលទស្សនាចុងក្រោយថ្ងៃទី២៣ មិថុនា ២០២១)
- ដកស្រង់ចេញពី https://data.opendevelopmentmekong.net/dataset/dea398c4-4242-480e-ad76-93820a1497d9/resource/a253a536-7032-43bd-b14e-cbef362c3948/download/2-executive-summary (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុន ឆ្នាំ២០២១)
- អាកាសយានដ្ឋានក្រុងព្រះសីហនុអាចនឹងក្លាយ ជាព្រលានយន្តហោះធំជាងគេនៅកម្ពុជា. ២០១៧, ដកស្រង់ចេញពី https://www.realestate.com.kh/km/news/sihanoukville-airport-to-become-the-largest-airport-in-cambodia/ (ចូលទស្សនាចុងក្រោយថ្ងៃទី មិថុនា ២០២១)
- ខេត្តព្រះសីហនុ, ដកស្រង់ចេញពី https://visitcambodia.travel/kh/province/view/6454a48474t2943423s2 (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១)
- ដកស្រង់ចេញពី នគរបាលជាតិកម្ពុជា និងក្រសួងសន្តិសុខចិន ជួបពិភាក្សាគ្នាជុំវិញ បញ្ហាសន្តិសុខនៅខេត្តព្រះសីហនុ - ក្រសួងព័ត៌មាន (information.gov.kh) (ចូលទស្សនាចុងក្រោយថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២១) ដកស្រង់ចេញពី អាជ្ញាធរក្រុងព្រះសីហនុ ចុះរៀបចំសណ្ដាប់ធ្នាប់ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងឱកាសថ្ងៃឈប់សម្រាក | សារព័ត៌មាន នគរវត្ត (nokorwatnews.com) (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១)
- ធនធានមនុស្សក្នុងវិស័យសំណង់នៅកម្ពុជាត្រូវពង្រឹងបន្ថែមលើសមត្ថភាពជំនាញបីធំៗ ដកស្រង់ចេញពី https://www.construction-property.com/km/pm-cambodias-construction-human-resources-must-strengthen-their-capacity/ (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១)
- ក្រសួងសាធារណការ និង ដឹកជញ្ជូន គម្រោងសាងសង់ផ្លូវ១១ ខ្សែ តម្លៃ១០០លានដុល្លារនៅខេត្តព្រះសីហនុ សម្រេចបានជាង ២១%ហើយ ២០២១, ដកស្រង់ចេញពី https://mpwt.gov.kh/kh/press/15942 (ចូលទស្សនាចុងក្រោយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១)

# ឧបសម្ព័ន្ធរូបភាព



រូបភាពទី១ ៖ រង្វង់មូលតោពីរនៅក្នុងក្រុងព្រះសីហនុ



រូបទី២ ៖ សោភ័ណភាពពេលយប់នៅក្រុងព្រះសីហនុ



រូបទី៣ ៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ



រូបទី៤ ៖ គំរូសួនច្បារក្រុងព្រះសីហនុ



រូបទី៥ ៖ គំរូទិដ្ឋភាពតាមដងឆ្នេរសមុទ្រក្រុងព្រះសីហនុ



រូបទី៦ ៖ ឆ្នេរអូរឈើទាលក្រុងព្រះសីហនុ



រូបទី៧ ៖ សោភ័ណភាពពេលថ្ងៃនៅក្រុងព្រះសីហនុ



រូបទី៨ ៖ គំរូហេដ្ឋារចនាសម្ព័ន្ធនៅក្រុងព្រះសីហនុ




រូបទី៩ ៖ អគារពាណិជ្ជកម្មនៅក្រុងព្រះសីហនុ



រូបទី១០ ៖ ការសាងសង់ស្ថានីយបូមទឹកកខ្វក់នៅក្រុងព្រះសីហនុ



រូបទី១១ ៖ អាងប្រព្រឹត្តកម្មទឹកកខ្វក់ព្រះសីហនុ



រូបទី១២ ៖ ការសាងសង់ផ្លូវថ្នល់




រូបទី១១ ៖ ផែនទី ផែនការរៀបចំដែនដីនៅខេត្តព្រះសីហនុ

# ឧបសម្ព័ន្ធគតិយុត្ត

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** ៖ អនុក្រឹត្យលេខ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការបំពុលដោយសំឡេង

**ឧបសម្ព័ន្ធទី២** ៖ អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក

**ឧបសម្ព័ន្ធទី៣** ៖ អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ ចូលដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា

# ឧបសម្ព័ន្ធទី១ ៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់
# និងការរំខានដោយសំលេង

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំនត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង ។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

# ឧបសម្ព័ន្ធទី២ ៖

## អនុក្រឹត្យ
## ស្តីពី
## ការត្រួតពិនិត្យការបំពុលទឹក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

លេខ : ២៧ អ.ន.ក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការត្រួតពិនិត្យការបំពុលទឹក**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៨/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"**តំបន់ទឹកសាធារណៈ**" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"**ប្រភពបំពុល**" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"**សំណល់រាវ**" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"**ទឹកស្អុយ**" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"**សំណល់រឹង**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"**សំរាម**" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"**សារធាតុបំពុល**" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

# ឧបសម្ព័ន្ធទី៣ ៖

# អនុក្រឹត្យស្តីពី
# ការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួត
# ពិនិត្យទំនិញនាំចេញ ចូលដើម្បីសម្រួល
# ពាណិជ្ជកម្ម និងពង្រឹងភាពប្រកួត
# ប្រជែងកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** [illegible]....អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ-នាំចូល**

**ដើម្បីសម្រួលពាណិជ្ជកម្ម និង ពង្រឹងភាពប្រកួតប្រជែងកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញបានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**សម្រេច**

**មាត្រា១.-**

ត្រូវបានបញ្ចប់តួនាទីនិងភារកិច្ចត្រួតពិនិត្យទំនិញនាំចេញ-នាំចូល របស់អគ្គនាយកដ្ឋានកាំកុងត្រូលនិងក្រុមហ៊ុនត្រួតពិនិត្យទំនិញ ទីហៅណៃ អាហារណៃ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម ពីច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទេសភាគី ច្រកទ្វារតំបន់ព្រំដែន ច្រកទ្វារកំពង់ផែសមុទ្រ តំបន់សេដ្ឋកិច្ចពិសេស ទីកន្លែងសម្អិតកម្មបណ្តោះអាសន្ន និងទីកន្លែងត្រួតពិនិត្យទំនិញនាំចេញ-នាំចូលផ្សេងទៀត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាស្ថាប័នតែមួយគត់មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យទំនិញនាំចេញ-នាំចូល នៅច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទេសភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ តំបន់សេដ្ឋកិច្ចពិសេស ទីកន្លែងសម្អិតកម្មបណ្តោះអាសន្ន និងទីកន្លែងត្រួតពិនិត្យទំនិញនាំចេញ-នាំចូលផ្សេងទៀត ។